# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Nov-2012, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារិត

---


ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Joshua ROSENSWEIG
Sofie HOGESTOL
Renee DE GUES

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី**

PICH Ang
Elisabeth SIMONNEAU-FORT

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ការិយាល័យសហព្រះរាជអាជ្ញាដាក់សំណើសុំការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូងថា កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងអស់អាចទទួលយកជាភស្តុតាង ឲ្យតែកំណត់ហេតុទាំងនោះពាក់ព័ន្ធ និងមានតម្លៃដែលអាចបញ្ជាក់បាន ("សំណើដើមរបស់ កសព)[1]។ ក្រុមមេធាវីការពារ នួន ជា ឆ្លើយតបថា អនុលោមតាមក្រមនីតិវិធី និងតាមវក្យសព្ទយ៉ាងច្បាស់នៃវិធានផ្ទៃក្នុង និងដោយមានការលើកលែងបន្តិចបន្តួចមួយចំនួនពោលគឺ សិទ្ធិតទល់សាក្សីដែលជាសិទ្ធិដាច់ខាត[2]។ អាស្រ័យហេតុនេះកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងឡាយណា ដែលនឹងមិនត្រូវបានកោះហៅឲ្យចូលខ្លួនមកផ្តល់សក្ខីកម្មនៅសវនាការ មិនអាចទទួលយកជាភស្តុតាងបានឡើយ។ ជនជាប់ចោទ ដទៃទៀតដាក់ការឆ្លើយតបស្រដៀងគ្នានេះ[3]។

២. នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងសម្រេចថាវិធាននិតីវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិដែលស្តីពីការទទួលយកជាភស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីបាន

---

[1] ឯកសារ E-96 "ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុ នៃការស្តាប់ចម្លើយសាក្សីនៅចំពោះអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ERN 00706071-00706086 ("សំណើដើមរបស់ កសព")។

[2] ឯកសារ E-96/1 "សារណាឆ្លើយតបទៅនឹងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី" ចុះថ្ងៃទី២១ កក្កដា២០១១ ERN ០០៧១៦៩៦៩-០០៧១៦៩៧៨, កថាខណ្ឌទី៣-៥

[3] ឯកសារ E-96/2 "សារណាឆ្លើយតបទៅនឹងដីការសន្និដ្ឋានរបស់ កសព របស់មេធាវីការពារ អៀង ធីរិទ្ធ ទាក់ទងនឹង ការ ទទួលយកជាភស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១១ ERN 00715984-00715999 ។ សូមមើលឯកសារ E-96/3 "សារណាឆ្លើយតបរបស់មេធាវីការពារ អៀង សារី ទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនៅចំពោះអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំសវនាការជាសាធារណៈ" ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១១ ERN 00718446-00718461 ។ សូមមើលឯកសារលេខ E-96/4 ស្តីពីការកត់សម្គាល់នៅសារណាឆ្លើយតបទៅនឹង ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនៅចំពោះអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ , ERN 00721872-00721882។

អនុវត្តចំពោះដំណើរការនិតីវិធីនៅ អវតក (“សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ”[4]។ នៅក្នុងការសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានអនុម័តយករបបគតិយុត្តិដោយគ្មានបញ្ជាក់ពីគុណសម្បត្តិ នៃនីតិវិធីនេះ នៅក្នុងតុលាការមិនអចិន្ត្រៃយ៍(“វិធាន៩២ស្ទួននៃវិធាននិតីវិធីនិងភស្តុតាង”)។ អនុលោមតាមសេចក្តីសម្រេចនោះ សហព្រះរាជអាជ្ញាដាក់សំណើនេះសុំឱ្យទទួលយកជាភស្តុតាងនៅក្នុងករណី ០០២ នូវឯកសារមិនតិចជាង ១៣៩៤ ដែលជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងសក្ខីកម្ម ៩០ ថ្ងៃនៃសវនាការនៅក្នុងករណី០០១ (“សំណើបន្ថែមរបស់ កសព”)[5]។

៣. សំណើដែលមានវិសាលភាពដ៏ធំបែបនេះ- កំណត់ហេតុស្ទើរតែ ១ ៤០០ ទៅហើយ តទល់នឹងសាក្សីនៅរស់តែ ៩០ នាក់[6]- នោះអាចឱ្យអង្គជំនុំជម្រះមានក្តីបារម្ភជាពុំខានឡើយ។ បើតាមមេធាវីការពារក្តីដឹងសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលមានទំហំធំដូច កសព បានស្នើរនេះ មិនដែលត្រូវបានទទួលយកជាភស្តុតាងឡើយនៅតុលាការព្រហ្មទណ្ឌអន្តរជាតិមួយ បន្ទាប់ពីបានពិនិត្យវិធាន៩២ស្ទួនដោយផ្អែកលើសញ្ញាណនៃវិធាននីតិវិធីនិងភស្តុតាងនៅ ICTY និង ICTR មេធាវីការពារក្តីមិនដែលជួបប្រទះករណីដែលភាគីមួយស្វែងរកការដាក់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីច្រើនជាង ១៣០ បែបនេះ នៅ

---

[4] ឯកសារ E-96/7 “សេចក្តីសម្រេចលើដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនៅចំពោះអង្គជំនុំជម្រះសាលាដំបូង” ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ERN 00812146-00812163 (“សេចក្តីសម្រេចរបស់ អជសដ”)

[5] ឯកសារ E-96/8 “សំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ និងប្រតិចារិក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់១ ដល់១៦” ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ ERN 00828859-00828873 “សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា”)។

[6] ឯកសារ E-131/1.1 “ឧបសម្ព័ន្ធសំងាត់ក: បញ្ជីមិនពេញលេញនៃឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការជំនុំជម្រះក្តីដំណាក់កាលដំបូងនៅក្នុងករណី០០២ ERN 00747687-00747694 ។ ឯកសារលេខ E236/1.1 អនុស្សាណៈរបស់សាលាដំបូងស្តី “ពីការបញ្ជាក់ជាបឋមនូវបុគ្គលដែលអង្គជំនុំជម្រះ ត្រូវស្តាប់សក្ខីកម្មក្នុងអំឡុងសវនាការលើចំណុចអង្គហេតុដែលពាក់ព័ន្ធ នឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង ០០២/០១” ចុះថ្ងៃទី ២ តុលា ឆ្នាំ ២០១១ ERN ០០៨៥០១៤៧-០០៨៥០១៤៨ ។

ក្នុងញត្តិមួយ (ដែលមានសក្ខីកម្ម ៥១ នាក់ត្រូវបានទទួលយកដោយមិនមានការសួរដេញដោល)[7]។ ក្នុងអំឡុងពេលពីរឆ្នាំកន្លះក្នុងករណីសវនាការ *Karadzic* មានសក្ខីកម្មរបស់សាក្សីចំនួន ២៣៩ ដែលស្នើដាក់ជាភស្តុតាង ដែលក្នុងនោះកំណត់ហេតុ ១២៨ ត្រូវបានគេទទួលយកជាភស្តុតាងដោយគ្មានការសួរដេញដោលដោយបដិភាគី[8]។ តាមរយៈការស្នើដាក់ឯកសារដ៏ច្រើនបែបនេះ សំណើរបស់សហព្រះរាជអាជ្ញានឹងធ្វើឲ្យប៉ះពាល់ដល់ភាពប្រក្រតីនៃការអនុវត្តដែលកំពុងធ្វើ របស់តុលាការអន្តរជាតិនានា។

[7] ករណីព្រះរាជអាជ្ញា ទល់នឹង Tolimir IT-05-088/2-T "សេចក្តីសម្រេចស្តីពីញត្តិរបស់ព្រះរាជអាជ្ញាក្នុងការទទួលយក នូវភស្តុតាងជាលាយលក្ខណ៍អក្សរ អនុលោមតាមវិធាន ៩២ ស្ទួន និង ៩៤ ស្ទួន" ចុះថ្ងៃទី ០៧កក្កដា ២០១០ បញ្ញត្តិកថាខណ្ឌ ទី២ចំណុចក។

[8] *ករណីរដ្ឋអាជ្ញា តទល់ Karadzic,* IT-95-5/18-T "សេចក្តីសម្រេចលើញត្តិទីមួយរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនូវកំណត់ហេតុ និងប្រតិចារិតនៃភស្តុតាងជំនួសសក្ខីកម្មផ្ទាល់មាត់អនុលោមតាមវិធាន ៩២ស្ទួន (សាក្សីសម្រាប់១១ទីក្រុង) ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩។ "សេចក្តីសម្រេចបន្ថែមលើញត្តិលើកទីមួយរបស់ព្រះរាជអាជ្ញាអនុលោមតាមវិធាន៩២ស្ទួន (សាក្សីសម្រាប់១១ក្រុង") ចុះថ្ងៃទី៩ ខែកុម្ភៈឆ្នាំ២០១០។ "សេចក្តីសម្រេចលើញត្តិលើកទីពីររបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារិតនៃភស្តុតាងជំនួសសក្ខីកម្មផ្ទាល់មាត់អនុលោមតាមវិធាន ៩២ស្ទួន (សាក្សីសម្រាប់ទីក្រុង ARK) ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១០ ។ "សេចក្តីសម្រេចលើញត្តិលើកទីពីររបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនូវភស្តុតាង Slobodan Stojkovic ជំនួសសក្ខីកម្មផ្ទាល់មាត់អនុលោមតាមវិធាន ៩២ស្ទួន" ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ២០១២ ។ "សេចក្តីសម្រេចលើញត្តិលើកទីបីររបស់ព្រះរាជអាជ្ញាសុំទទួលយកភស្តុតាងនូវកំណត់ហេតុ និងប្រតិចារិតនៃភស្តុតាង ជំនួសសក្ខីកម្មផ្ទាល់មាត់អនុលោមតាមវិធាន ៩២ស្ទួន (សាក្សីសម្រាប់ទីក្រុង Sarajevo" ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៩ ។ "សេចក្តីសម្រេចលើញត្តិលើកទីបួនររបស់ព្រះរាជអាជ្ញាសុំទទួលយកភស្តុតាងនូវកំណត់ហេតុ និងប្រតិចារិតនៃភស្តុតាង ជំនួសសក្ខីកម្មផ្ទាល់មាត់អនុលោមតាមវិធាន ៩២ស្ទួន (សាក្សីសម្រាប់ការចូលកាន់កាប់ទីក្រុង Sarajevo" ចុះថ្ងៃទី៥ ខែមិនា ឆ្នាម២០១០ ។ "អត្ថបទកោសលុបសាធារណៈនៃ"សេចក្តីសម្រេចលើញត្តិលើកទីប្រាំររបស់ព្រះរាជអាជ្ញាសុំទទួលយកភស្តុតាងនូវកំណត់ហេតុ និងប្រតិចារិតនៃភស្តុតាង ជំនួសសក្ខីកម្មផ្ទាល់មាត់អនុលោមតាមវិធាន ៩២ស្ទួន (សាក្សីសម្រាប់ទីក្រុង Srebrenica) ចេញនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩, 6 មីនា២០១២ ។ "សេចក្តីសម្រេចកោះហៅ Drazen Erdemovic ដើម្បីសួរតទល់ដោយបដិភាគី" ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ ។ "សេចក្តីសម្រេចលើញត្តិលើកទីប្រាំមួយររបស់ព្រះរាជអាជ្ញាសុំទទួលយកភស្តុតាងនូវកំណត់ហេតុ និងប្រតិចារិតនៃភស្តុតាង ជំនួសសក្ខីកម្មផ្ទាល់មាត់អនុលោមតាមវិធាន ៩២ស្ទួន (សាក្សីទាក់ទងនឹងចំណាប់ខ្មាំង" ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០៩។ "សេចក្តីសម្រេចលើញត្តិលើកទីប្រាំពីររបស់ព្រះរាជអាជ្ញាសុំទទួលយកភស្តុតាងនូវកំណត់ហេតុ" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩។ "សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនូវភស្តុតាងរបស់ Milan Tupajic ជំនួសសក្ខីកម្មផ្ទាល់មាត់ អនុលោមតាមវិធាន៩២

៤. នីតិវិធីព្រហ្មទណ្ឌអន្តរជាតិមុនៗទាំងនេះអាចនឹងមិនងាយត្រូវបានចោទប្រកាន់ចំពោះ បញ្ហាវិសាលភាព ឬភាពស្មុគស្មាញពេក ដូចករណី០០២ នោះទេ។ តាមពិតបទពិសោធន៍នៃតុលាការមិនអចិន្ត្រៃយ៍ នានាកន្លងមកដែលគេគោរព គឺសំដៅលើហេតុផលជាគោលការណ៍មួយដែលតម្រូវឲ្យអង្គជំនុំជម្រះប្រើប្រាស់វិធាន៩២ស្ទួន យកមកដាក់ជាអាទិភាព[9]។ ហេតុដូច្នេះ អង្គជំនុំជម្រះគប្បីមានមន្ទិលសង្ស័យទៅលើជំហយ៉ាងច្បាស់របស់សហព្រះរាជអាជ្ញាដែលនៅក្នុងករណី០០២ មានការទាមទារឲ្យមានការលើកលែងជាពិសេសចំពោះសិទ្ធិរបស់ជនជាប់ចោទក្នុងការតទល់ទៅនឹងសាក្សីប្រឆាំងនឹង រូបគាត់ច្រើនជាងការអនុវត្តនៅអង្គជំនុំជម្រះដែលមានអាយុកាលពីរទសវត្សរ៍កន្លងមកដូចជានៅតុលាការ ICTR និង ICTY[10]។

៥. តុលាការវិសាមញ្ញជាច្រើន កម្រិតចំនួនកំណត់ហេតុដែលត្រូវទទួលយកជាភស្តុតាង ដោយមិនចាំបាច់មានការសួរដេញដោលនៅសវនាការ ពីព្រោះនិតីវិធីនោះឋិតនៅក្រោមលក្ខខណ្ឌរឹតបន្តឹងបំផុតនៅក្រោមវិធាន៩២ស្ទួន។ ការរឹតត្បិតទាំងនេះគឺជាចំនុចស្នូលនៃរបបគតិយុត្តិ(របស់មាត្រា៩២ស្ទួន) ដែលមានគោលដៅធ្វើឲ្យដំណើរការមានប្រទាក់ក្រឡាគ្នាក្នុងការអនុវត្ត។ នៅក្នុងការសម្រេចថាវិធាន៩២ស្ទួន អនុវត្តចំពោះនិតីវិធីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងបញ្ចូលរបបគតិយុត្តិកម្រិតអន្តរជាតិ ដោយផ្អែកទាំងស្រុងលើច្បាប់ស្តីពីការបង្កើតតុលាការវិសាមញ្ញនានា ទៅក្នុងនិតីវិធីរបស់ អវតក។ នៅក្រោមកាលៈទេសៈបែបនេះ អង្គជំនុំជម្រះត្រូវតែអនុវត្តរបបគតិយុត្តិនេះទាំងមូល ដោយប្រយ័ត្នប្រយែងនៅ

ស្ទួន" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ។ "សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងរបស់អ្នកជំនាញប្រាំរូបអនុលោមតាមវិធាន៩២ស្ទួននិង ៩៤ស្ទួន" ចុះថ្ងៃទី៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

[9] សេចក្តីសម្រេចរបស់ជំនុំជម្រះនៅកថាខណ្ឌ១៩ ។

[10] អង្គជំនុំជម្រះមិនគួរ ធ្វើឲ្យមានការភាន់ភាំង តាមរយៈសារជាតិនៃច្បាប់ស៊ីវិលចំពោះនីតិវិធីទាំងនេះទេ ។ នីតិវិធីកម្ពុជាគឺមានអានុភាព ចំពោះអង្គជំនុំជម្រះ ហើយចំពោះក្រុមមេធាវីការពារក្តីទាំអស់ បានជំរុញ អង្គជំនុំជម្រះឲ្យគោរពតាមនីតិវិធីទាំងនោះ។ អង្គជំនុំជម្រះ បានប្រកាន់នូវជំហរផ្សេងជំនួសវិញដោយអះអាងថា វិធាន និង យុត្តិសាស្ត្រ នៃតុលាការ មិនអចិន្ត្រៃយ៍ គឺអាចយកមកអនុវត្តបាន។ នៅក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញា បានសន្និដ្ឋានថា ការទទួលយកនូវកំណត់ហេតុសាកសួរទាំងនេះជាភស្តុតាង គឺជាការសមរម្យ ចំពោះសវនាការឧក្រិដ្ឋកម្មដែលមានលក្ខណស្មុគស្មាញ និងប្រញាប់ប្រញាល់មួយ ហើយដែលជាការស្នើ ឡើងដែលអះអាងដោយ យោលទៅលើបទពិសោធន៍ ដែលមាននៅ ICTY/R។ សូមមើល សំណើដំបូង របស់ការិយាល័យ សហព្រះរាជអាជ្ញា, កថាខណ្ឌ ២៦។

ក្នុងដំណើរការរបស់ខ្លួន ហើយមិនត្រូវយក និងជ្រើសរើសវិធានណាដែលសេរីពេក ក្នុងការទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីឡើយ។ សម្រាប់មូលហេតុខាងក្រោម ការអនុវត្តទាំងស្រុងនូវរបបគតិយុត្តិនៃវិធាន ៩២ស្ទួន នាំឲ្យមានការទាត់ចោលនូវកំណត់ហេតុសំខាន់ៗយ៉ាងច្រើនដែលស្នើឡើងដោយសហព្រះរាជអាជ្ញា។ វិធីសាស្ត្រមិនសូវតឹងរឹង ពាក់ព័ន្ធនឹងការអនុវត្តរបបគតិយុត្តិដែលមានលក្ខណៈដូចតិចតួចទៅនឹងវិធាន ៩២ស្ទួន ហើយជាហេតុនាំឲ្យមានការរំលោភទៅនឹងការអះអាងដើមនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាអង្គជំនុំជម្រះនេះកំពុងតែប្រើប្រាស់ "និតីវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ"។ វាក៏ចាត់ទុកផងដែរថាជាការរំលោភធ្ងន់ធ្ងរដល់សិទ្ធិសួរដេញដោល និងសិទ្ធិទទួលបានការកាត់ក្ដីដោយយុត្តិធម៌។

## II. ច្បាប់ដែលពាក់ព័ន្ធ

## ក. បទដ្ឋាន នានាសម្រាប់ការទទួលយកជាភស្តុតាងនៅក្រោមវិធាន៩២ស្ទួន

### i- ទំនាក់ទំនងរវាងវិធាន ៩២ស្ទួន(ក) និង(គ)

៦. អនុលោមតាមវិធាន ៩២ស្ទួន នៃវិធានស្ដីពីនិតីវិធីនិងភស្តុតាង ការទទួលជាភស្តុតាងនូវកំណត់ហេតុមុនៗជំនួសឲ្យការផ្ដល់ចម្លើយនៅសវនាការ និងការទទួលជាភស្តុតាងនូវកំណត់ហេតុជំនួសឲ្យការសួរដេញដោលដោយបដិភាគី ត្រូវបានចេញជាពីរផ្នែកនិងត្រូវបានវិភាគជាបន្តបន្ទាប់[11]។ ជាបឋមអង្គជំនុំ

---

[11] *ករណីរដ្ឋអាជ្ញា តទល់ Milutinovic*, IT-05-87-T, 'សេចក្ដីសម្រេចលើញត្តិរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៩២ស្ទួន" ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៦ ("សេចក្ដីសម្រេច *Milutinovic* កក្កដា ០៦) កថាខណ្ឌ ១៥ដល់ ១៩ (ពិចារណាកត្តានានាចែងនៅក្នុងវិធាន៩២ស្ទួន (ក) ហើយបន្ទាប់មកការសួរដេញដោលបដិភាគី)។ *ករណីរដ្ឋអាជ្ញា តទល់ Milosevic*, IT-02-54-T, 'សេចក្ដីសម្រេចលើញត្តិរបស់ ព្រះរាជអាជ្ញាសុំឲ្យទទួលយកជាភស្តុតាងនូវប្រតិចារិកជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់អនុលោមតាមវិធាន៩២ស្ទួន(ឃ)-ប្រតិចារិក Foca ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ (សេចក្ដីសម្រេច *Milosevic* មិថុនា០៣)នៅកថាខណ្ឌ១០ ("មានបីជំហាននៅក្នុងការធ្វើសេចក្ដីសម្រេចណាមួយនៅក្រោមវិធាន៩២ស្ទួនៈ ជំហាន (i) ថាតើប្រតិចារិត អាចត្រូវទទួលយកជាភស្តុតាងនៅក្រោមវិធាន៩២ស្ទួនដែរ ឬអត់(ប្រសិនបើវាកាពារសកម្មភាព និងទង្វើរបស់ជនជាប់ចោទដូចមានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះ នោះវានឹងមិន អាចទទួលយកជាភស្តុតាងបានទេ, ជំហាន(ii) តាមការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះប្រតិចារិកដែលអាច ឬមិន អាច យកជាភស្តុតាងបានត្រូវមានហេតុផលជាជាសំអាងពីអង្គជំនុំជម្រះ និងជំហាន (iii) ប្រសិនបើប្រតិចារិកមួយត្រូវបានទទួលយក ល្គឹកណាសាក្សីដែលសក្ខីកម្មរបស់ខ្លួនមាននៅក្នុងប្រតិចារិត បានបង្ហាញខ្លួនសម្រាប់ការសួរដេញដោលដោយភាគីបដិបក្ខ")។ *ករណី រដ្ឋអាជ្ញា តទល់ Karadzic* IT-95-5/18-PT, សេចក្ដីសម្រេចលើញត្តិលើកទីបីរបស់ព្រះរាជអាជ្ញា

ជម្រះ ត្រូវសម្រេចភាពអាចទទួលយកបានស្របតាមវិធាន៩២ស្ទួន(ក) ហើយបន្ទាប់អង្គជំនុំជម្រះពិចារណាថា ការទទួលយកគួរតែតម្រូវឲ្យមកបង្ហាញខ្លួននៅសវនាការសម្រាប់ការសួរដេញដោលដោយបដិភាគីនៅក្រោមវិធាន៩២ស្ទួន(គ)ដែរ ឬយ៉ាងណា។ ការវិភាគទាំងពីរនេះពាក់ព័ន្ធនឹងសួរចម្លើយសាក្សីជាន់គ្នា ប៉ុន្តែជាការពិចារណាដាច់ពីគ្នា ។

៧. សំណើនេះពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ១ ៤០០ នាក់ ដែលភាគច្រើននឹងមិនត្រូវសួរដេញដោលនៅសវនាការនោះទេ។ ចំពោះសាក្សីទាំងអស់នេះ បទដ្ឋានពាក់ព័ន្ធដែលអាចអនុវត្តចំពោះការទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ដោយមិនចាំបាច់តម្រូវឲ្យមានការសួរដេញដោលពីបដិភាគីនៅក្រោមវិធាន៩២ស្ទួន(គ) មិនមែនជាបទដ្ឋានទាបជាងដែលអនុវត្តចំពោះការទទួលយកជាភស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដោយមិនចាំបាច់តម្រូវឲ្យមានការបង្ហាញខ្លួនសាក្សីនៅក្រោមវិធាន៩២ស្ទួន(ក)។ ករណីដែលទាញចេញពី តុលាការមិនអចិន្ត្រៃយ៍ នានាដែលពាក់ព័ន្ធតែចំពោះការទទួលយកជាភស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនៅក្រោមវិធាន៩២ស្ទួន(ក) ដោយគ្មានការចង្អុលបង្ហាញច្បាស់លាស់ថាជនជាប់ចោទមិនមានសិទ្ធិសួរដេញដោលសាក្សីប្រឆាំងនឹងគាត់ គឺមិនពាក់ព័ន្ធអ្វីទាំងអស់នឹងការវិភាគនេះទេ[12]។

៨. បើទោះបីជាភាពខុសគ្នារវាងដំណាក់កាលទាំងពីរនៃការវិភាគនេះ ត្រូវបានទទួលស្គាល់នៅក្នុងសំណើដើមរបស់សហព្រះរាជអាជ្ញាក៏ដោយ[13] ក៏វាមិនបានលើកឡើងឲ្យបានច្បាស់នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែរ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចង្អុលបង្ហាញថាការទទួលយកជាភស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលមិនស្របជាមួយអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ នឹងត្រូវបានពិចារណាដោយអនុលោមតាមការវាយតម្លៃផ្អែកលើកត្តាប្រាំ

---

សុំទទួលយក ជា ភស្តុតាង នូវ កំណត់ហេតុ និងប្រតិចារិតនៃភស្តុតាង ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ អនុលោមតាមវិធាន៩២ស្ទួនសាក្សីសម្រាប់ប្រជាពលរដ្ឋទីក្រុង Sarajevo” ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៩ (“សេចក្តីសម្រេច *Karadzic* តុលា០៩) នៅកថាខណ្ឌ ៥-៩ (ការវិភាគនៅក្រោមវិធាន៩២ ស្ទួន(ក) នៅកថាខណ្ឌ១០ (អនុវត្តតាមការវិភាគនៅក្រោមវិធាន៩២ស្ទួន(គ)។

[12] មេធាវីការពារក្តីទទួលស្គាល់ថា ការពិចារណាខុសគ្នា ដែលអនុវត្តសម្រាប់សាក្សីមួយរូបដែលទទួលមរណៈ ឬក៏មិនអាចមកបាន។ ការទទួលយកតាមមូលដ្ឋានបែបនោះនឹងតម្រូវឲ្យមានការបង្ហាញពីភាពមិនអាចមកបាន។ សូមមើល សេចក្តីសម្រេច អជសដ កថាខណ្ឌ ៣២ ដល់ ៣៣។

[13] សំណើដើមរបស់ កសព កថាខណ្ឌ ១៣។

ចំណុចដែលយកចេញពីវិធាន៩២ស្ទួន(ក)(i)។ នៅពេលភាពអាចទទួលយកត្រូវបានសម្រេចតាមវិធាន៩២ស្ទួន(ក) ហេតុដូច្នេះអវត្តមាន នៃសក្ខីកម្មផ្ទាល់មាត់ និងឱកាសតទល់សាក្សីប្រឆាំងនឹងខ្លួន គឺជាការពិចារណាដែលមានការពាក់ព័ន្ធ ហើយថាតម្លៃដែលអាចបញ្ជាក់បាន និងទម្ងន់របស់ភស្តុតាងដែលស្របនឹងភស្តុតាងបែបនេះនៅក្នុងកាលៈទេសៈមួយចំនួន អាចត្រូវបានកម្រិត[14]។ វានៅមិនច្បាស់ថា តើអង្គជំនុំជម្រះ មានបំណរក្សាជំហាថា ការថមថយទម្ងន់របស់ភស្តុតាង គឺជាផលវិបាកពាក់ព័ន្ធតែមួយគត់នៃការគ្មានឱកាសសួរដេញដោលដោយបដិភាគីឬយ៉ាងណា[15]។

៩. មិនមែនជាស្រមោលនៃការមន្ទិលសង្ស័យនៅតុលាការមិនអចិន្ត្រៃយ៍នានា តែជាការខកខានមិនអនុញ្ញាតឱ្យមានឱកាសតទល់គ្នា ប៉ះពាល់ដល់ការទទួលយកភស្តុតាង។ នៅក្រោមវិធាន៩២ស្ទួន បន្ទាប់ពីសម្រេចថា កំណត់ហេតុមួយបំពេញបានតេស្តដែលមានចែងនៅក្នុងវិធាន៩២ស្ទួន(ក) តុលាការមានកាតព្វកិច្ចពិចារណាថា តើសាក្សីត្រូវតែចូលខ្លួនដើម្បីផ្តល់ចម្លើយនៅសវនាការស្របតាមវិធាន៩២ស្ទួន(គ)ដែរ ឬយ៉ាងណា[16]។ នៅក្នុងករណីនេះកំណត់ហេតុនឹងត្រូវបានទទួលយកជាភស្តុតាង បើសិនសាក្សីមានវត្តមាននៅតុលាការ និងអាចសួរដេញដោលដោយបដិភាគី[17]។ ការសន្និដ្ឋាននេះទាញចេញ

---

[14] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅកថាខណ្ឌ២៥។

[15] ក្នុងការពិពណ៌នា កាលៈទេសៈថាតើការស្តាប់ចម្លើយណាមួយអាចទទួលយកបាន អង្គជំនុំជម្រះបានដក់ស្រង់យុត្តិសាស្ត្រ ដោយសង្ខេបកត្តាដែលទាក់ទងទៅនឹងវិធាន ៩២ស្ទួន (គ) ប៉ុន្តែមិនបានពន្យល់ពីតួនាទីនៃកត្តាទាំងនោះនឹងអាចមានតួនាទីក្នុងការវិភាគរបស់អង្គជំនុំជម្រះ។ សូមមើល សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣១ និង ជើងទំព័រ ៥០។

[16] សូមមើលអក្សរក្នុងជើងទំព័រ ១១ ខាងលើ ។

[17] វិធាន៩២ស្ទួន (ter)(ក)(i)-(iii)។ សេចក្តីសម្រេច *Milutinovic* កក្កដា ០៦ នៅកថាខណ្ឌ១៩ (ទាក់ទងនឹងកំណត់ហេតុដែលតម្រូវឱ្យមានការសួរដេញដោលដោយបដិភាគីក្រោមវិធាន៩២ស្ទួន(គ) "វាជាការត្រឹមត្រូវក្នុងការទទួលយកជាភស្តុតាង ឱ្យតែសាក្សីនិមួយៗ..អាចឱ្យសួរដេញដោលបាន។ *ករណីរដ្ឋអាជ្ញា តទល់* *Karemera*, ICTR-98-44-T, 'សេចក្តីសម្រេចបន្ទាប់ពីការដាក់សេចក្តីសន្និដ្ឋានអនុលោមតាមវិធាន៩២ស្ទួន ដោយ Joseph Nzirorera (កំណត់ហេតុដែលមានការបញ្ជាក់ត្រឹមត្រូវ) ចុះថ្ងៃ១០ ខែកញ្ញា ឆ្នាំ២០០៩ ("សេចក្តីសម្រេច *Karemera* កញ្ញា ០៩") នៅកថាខណ្ឌ៤ ("ដោយយកចិត្តទុកដាក់ពីផលវិបាកដែលអាចកើតឡើង បើសិនសាក្សីគ្មានវត្តមានដើម្បីឱ្យសួរដេញដោលនៅសវនាការ" នោះកំណត់ហេតុនឹងមិនត្រូវបានទទួលយកជាភស្តុតាងទេ រហូតដល់សាក្សីបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ)។ *ករណីរដ្ឋអាជ្ញា តទល់* *Karadzic,* IT-95-5/18-T"សេចក្តីសម្រេចលើញត្តិលើកទីពីររបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារិតនៃភស្តុតាងជំនួសសក្ខីកម្មផ្ទាល់មាត់អនុលោមតាមវិធាន ៩២ស្ទួន (សាក្សីសម្រាប់ Arkទីក្រុង) ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១០ ("សេចក្តីសម្រេច *Karadzic* មិនា ២០១០)

ពីវាក្យសព្ទយ៉ាងច្បាស់នៃវិធាន៩២ស្ទួន(គ)៖ "អង្គជំនុំជម្រះត្រូវសម្រេច...ថាតើតម្រូវឲ្យសាក្សីចូលខ្លួនដើម្បីសួរដេញនៅសវនាការដែរ ឬយ៉ាងណា។ ប្រសិនបើមិនសម្រេចទេ បទប្បញ្ញត្តិ ឬវិធាន៩២ ស្ទួនបីត្រូវតែយកមកអនុវត្ត"។ អនុលោមតាមវិធាន៩២ស្ទួនបី "អង្គជំនុំជម្រះ*អាចទទួលយក*...ភស្តុតាងរបស់សាក្សីម្នាក់នៅក្នុងទម្រង់ជាកំណត់ហេតុជាលាយលក្ខណ៍អក្សរ..*នៅក្រោមលក្ខខណ្ឌខាងក្រោម:* (i) សាក្សីមានវត្តមាននៅតុលាការ (ii) សាក្សីអាចត្រូវសួរដេញដោលដោយបដិភាគីនៅសវនាការ

---

នៅកថាខណ្ឌ៤៩ (ការសម្រេចពីការទទួលយកត្រូវពន្យារពេល រហូតដល់សាក្សីបង្ហាញខ្លួនពិតប្រាកដនៅចំពោះមុខអង្គជំនុំជម្រះ)។ *ករណីរដ្ឋអាជ្ញា តទល់* *Milosevic* IT-02-54-T, 'សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំឲ្យទទួលយកជាភស្តុតាងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី អនុលោមតាមវិធាន៩២ស្ទួន" ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០០២ ("សេចក្តីសម្រេច *Milosevic* មិនា ០២") នៅកថាខណ្ឌ២៧ ("ករណីដែលសាក្សីមិនចូលខ្លួនដើម្បីឲ្យសួរដេញដោលនៅសវនាការទេ នោះកំណត់ហេតុរបស់គាត់នឹងមិនទទួលយកជាភស្តុតាងឡើយ)។ រឿងក្តីរដ្ឋអាជ្ញា តទល់ *Lukic,* IT-98-32/I-T ("សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងស្របតាមវិធាន៩២ស្ទួន" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៨ ("សេចក្តីសម្រេច *Lukic* សីហា ០៨") នៅកថាខណ្ឌ៣០ (ការទទួលយកប្រតិចារិតបន្ទាប់ពីបំពេញបានលក្ខខណ្ឌនានាដែលមានចែងនៅក្នុងវិធាន៩២ស្ទួនបី)។ *ករណីរដ្ឋអាជ្ញា តទល់* *Galic*, IT-98-29-AR73.2 'សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំទាក់ទងនឹងវិធាន៩២ស្ទួន(គ)" ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០២ ("សេចក្តីសម្រេច *Galic*") នៅកថាខណ្ឌ១៥ (ប្រសិនបើវិធាន៩២ស្ទួន(គ) បានបំពេញមានជម្រើសពីរដែលតុលាការអាចរកបាន គឺមិនទទួលយកជាភស្តុតាងនូវកំណត់ហេតុ ឬសម្រេចថា "ការគ្មានឱកាសដើម្បីសួរដេញដោលអ្នកផ្តល់កំណត់ហេតុ គឺជាការសម្រេចដោយត្រឹមត្រូវក្នុងការមិនទទួលយកជាភស្តុតាងនូវកំណត់នេះ"។ *ករណីរដ្ឋអាជ្ញា តទល់* *Martic*, IT-95-11-T, 'សេចក្តីសម្រេចលើសំណើរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនូវប្រតិចារិតស្របតាមវិធាន៩២ស្ទួន(ឃ) និងរបាយការណ៍អ្នកជំនាញ ស្របតាមវិធាន៩៤ស្ទួន" ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៦ ("សេចក្តីសម្រេច *Martic*" នៅកថាខណ្ឌ២០ (នៅករណីដែលការអន្តរាយនៃការទទួលយកកំណត់ហេតុ មិនអាចជួសជុលបានតាមរយៈការសួរដេញដោលនៅសវនាការ កំណត់ហេតុត្រូវតែបដិសេធមិនទទួលយកជាភស្តុតាង)។ *ករណីរដ្ឋអាជ្ញា តទល់* *Taylor*, SCSL-03-1-T, "សេចក្តីសម្រេចលើការជូនដំណឹង របស់ព្រះរាជអាជ្ញាអនុលោមតាមវិធាន៩២ស្ទួន សុំទទួលយកភស្តុតាងដែលពាក់ព័ន្ធក្នុងចំណោមបញ្ហាដទៃទៀតជាមួយ Kenema និងលើការជូនដំណឹងរបស់ព្រះរាជអាជ្ញាអនុលោមតាមវិធាន៩២ស្ទួន សុំទទួលយកភស្តុតាងសក្ខីកម្មមុនៗ" ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ ("សេចក្តីសម្រេច *Taylor*") (ការទទួលយកកំណត់ហេតុដែលតម្រូវឲ្យសួរដេញដោល គឺជាលក្ខខណ្ឌស្តីពីឱកាសពិតៗ ដើម្បីសួរដេញដោលនៅសវនាការ)។

និងអាចចោទសួរដោយចៅក្រម"។ និតិវិធីនោះត្រូវបានយកមកអនុវត្តជាទូទៅដោយអង្គជំនុំជម្រះនៃតុលាការមិនអចិន្ត្រៃយ៍ជាច្រើន[18]។

១០. សេចក្តីសម្រេចក្រោមវិធាន៩២ស្ទួនដែលតម្រូវឱ្យសាក្សីចូលខ្លួនដើម្បីសួរដេញដោលនៅសវនាការ ត្រូវបានគេយល់ថាជាការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ។ ប៉ុន្តែឆន្ទានុសិទ្ធិនោះត្រូវតែបានអនុវត្តឱ្យសមស្របតាមបទដ្ឋានដែលត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ ដែលកើតចេញពីយុត្តិសាស្ត្រ។ ការខកខានមិនទទួលស្គាល់ ឬមិនពិចារណាកត្តានានាតាមឆន្ទានុសិទ្ធិ ដែលជាប់ពាក់ព័ន្ធជាមួយវិធាន៩២ស្ទួន អាចបង្កើតឱ្យមានកំហុស[19]។

ii. បទដ្ឋានសម្រាប់ទទួលយកភស្តុតាងជំនួសឱ្យការសួរសាក្សីផ្ទាល់ខ្លួនស្របតាមវិធាន៩២ស្ទួន(ក)

១១. ដោយអនុវត្តតាមតុលាការមិនអចិន្ត្រៃយ៍នានា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងប្រកាន់ជំហរ ថាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី "ដែលផ្តល់សក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ" មិនអាចទទួលយកបានឡើយ[20]។ ជាចម្បង នៅមុនការវាយតម្លៃនៃការពិចារណាដទៃទៀត កំណត់ហេតុបែបនេះមិន

---

[18] សូមមើលជើងទំព័រ ១៦ ខាងលើ។ បើទោះបីវិធាន៩២ស្ទួនចែងពីការសម្រេច "ភាពអាចទទួលយកបាន" នៅក្រោមវិធាន៩២ស្ទួន(ក) ហើយជាបន្ទាប់សិទ្ធិសួរដេញដោលស្របតាមវិធាន៩២ស្ទួន(គ) ក៏ការវិភាគសន្មតថាសាក្សីដែលកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ខ្លួន ត្រូវបានទទួលយកស្របតាមវិធាន៩២ស្ទួន(ក) សាក្សីនោះនឹងត្រូវសួរដេញដោលនៅសវនាការបើសិនជាតម្រូវដោយផ្អែកលើការវិភាគធ្វើឡើងស្របតាមវិធាន៩២ស្ទួន(គ)។ នៅក្នុងករណីនេះសាក្សីនឹងមិនត្រូវកោះហៅឱ្យចូលខ្លួនដើម្បីសួរដេញដោលនោះទេ បើទោះលទ្ធផលចេញពីការវិភាគស្របតាមវិធាន៩២ស្ទួន(គ) ជាអ្វីក៏ដោយ ។ នេះជាផលវិបាកកើតចេញពីចំនួនដ៏ច្រើននៃសម្ភារៈភស្តុតាងដែលមិនអាចប្រមើលដឹងជាមុនបាន រួមទាំងសម្ភារៈភស្តុតាងនៅក្នុងឧបសម្ព័ន្ធរបស់ កសព ផងដែរ។ វចនាសម្ព័ន្ធរបស់វិធានបង្ហាញថា អ្នកពង្រាងវិធានមិនបានប្រមើលទុកជាមុនថាសំណើសុំទទួលយកភស្តុតាងមានទំហំច្រើនបែបនេះទេ ដែលពិតជាមិនអាចកោះហៅសាក្សីឱ្យផ្តល់ចម្លើយនៅសវនាការបានឡើយ។

[19] សេចក្តីសម្រេច *Galic* នៅកថាខណ្ឌ១៨-២០ ។

[20] សេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤ (ខ)។

អាចទទួលយកជាស្វ័យប្រវត្តិបានទេ[21]។ ភស្តុតាងដែលមិនផ្តល់សក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ត្រូវតែបានពិចារណាដោយផ្អែកតាមកត្តាខុសៗគ្នាជាច្រើន ទាញចេញពីវិធាន៩២ស្ទួន(ក) និងបានពិភាក្សានៅកថាខណ្ឌ២៤ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅមុនការសម្រេចពីការទទួលយកភស្តុតាងជំនួសឲ្យសួរដេញដោលសាក្សីខ្លួនឯង[22]។

iii. <u>បទដ្ឋានសម្រាប់ការទទួលយកភស្តុតាងនូវកំណត់ហេតុ ជំនួសឲ្យការសួរដេញដោលសាក្សីនៅសវនាការដោយភាគីបដិបក្ខស្របតាមវិធាន ៩២ស្ទួន(គ)</u>

១២. កំណត់ហេតុដែលត្រូវបានទទួលយកជាភស្តុតាង ជំនួសឲ្យការសួរដេញដោលសាក្សីខ្លួនឯង ត្រូវតែបានសួរដេញដោលដោយបដិភាគីនៅសវនាការ (ឬបើមិនអញ្ចឹងទេ កំណត់ហេតុនេះត្រូវបដិសេធចោល) ប្រសិនបើវាមានសារៈសំខាន់គ្រប់គ្រាន់នៅក្នុងបរិបទប្រឆាំងនឹងជនជាប់ចោទ។ ភស្តុតាងបែបនេះរួមទាំងភស្តុតាងដែលផ្តល់សក្ខីកម្ម (i) ពីអំពើល្មើសដែលនៅជិតបំផុតនឹងជនជាប់ចោទ[23] និង(ii) បញ្ហាណាមួយរវាងភាគី ដែលខុសគ្នាពីបញ្ហាដែលមិនសូវមានសារៈសំខាន់ ឬដែលមានតែពីខាងក្រៅ[24]។

---

[21] សេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូង នៅកថាខណ្ឌ២១។ *រឿងក្តីរដ្ឋអាជ្ញា តទល់* *Nsabimana*, ICTR-97-29-T, ‘សេចក្តីសម្រេចលើសំណើរបស់ *Nsabimana* សុំឲ្យទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី Jami ដើម្បីស្តាប់សក្ខីកម្មផ្ទាល់មាត់ស្របតាមវិធាន៩២ស្ទួន” ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ (រៀបរាប់ពីអំពើ និងការប្រព្រឹត្តជា “ចំណុចផ្តើម”)។ ដោយអនុលោមតាមវិធាន ៩២ ស្ទួនបី (ខ) និងកថាខណ្ឌ ៣១ នៃ សេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូង ដែលភស្តុតាងបែបនេះអាចទទួលយកបាននៅពេលដែលការសួរដេញដោលត្រូវបានអនុញ្ញាត។

[22] សេចក្តីសម្រេច Milosevic ខែមិថុនា ២០០៣ កថាខណ្ឌ ១០-១៤។

[23] សេចក្តីសម្រេច Martic, នៅកថាខណ្ឌ ២០ (ភាពនៅជិតបំផុត គឺជាចំណុចស្នូលទាំងការទទួលយកភស្តុតាង និងការសួរដេញដោលដោយភាគីបដិបក្ខ)។ ករណី*រដ្ឋអាជ្ញា តទល់* *Karemera* ICTR-98-44-T “សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនៃអំពើរំលោភសេពសន្ថវៈ និងបំពារបំពានផ្លូវភេទ អនុលោមតាមវិធាន ៩២ស្ទួន នៃវិធានស្តីពីនិតីវិធី និងភស្តុតាង និងដីកាសម្រេចកាត់បន្ថយបញ្ជីសាក្សីដាក់បន្ទុក” ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៦ (“សេចក្តីសម្រេច *Karemera* ១១ ធ្នូ ០៦”) នៅកថាខណ្ឌ ១៥ (ភាពនៅជិតបំផុតនឹងអំពើ និងការប្រព្រឹត្តដូចមានរៀបរាប់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក់ព័ន្ធទៅនឹងការអនុវត្តធន្ទានុសិទ្ធិក្នុងការសួរដោញដោល) សេចក្តីសម្រេចរបស់ Karadiz នៅថ្ងៃទី០៩ ខែតុលា,កថាខណ្ឌ១០ (ដូចគ្នា)។ ករណីរដ្ឋអាជ្ញា តទល់ *Blagojevic,* IT-02-60-T “សេចក្តីសម្រេច ដំបូងលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់

១៣. បទដ្ឋានទាំងនេះគឺជាក់លាក់ ដែលផ្អែកលើការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ និងមេធាវីការពារក្តីដែលមានបំណងចង់បង្ហាញ។ ជាផលវិបាក វិធានត្រចះត្រចង់ មិនទាន់រកឃើញនៅឡើយទេ។ ប៉ុន្តែគោលការណ៍ខាងក្រោមដែលកើតចេញពីករណីយុត្តិសាស្ត្រ មានការពាក់ព័ន្ធជាពិសេសដល់ករណីនេះ[25]។

ក. នៅក្នុងករណីដែលការទទួលខុសត្រូវថ្នាក់លើត្រូវបានចោទប្រកាន់ សក្ខីកម្មទាក់ទងនឹងការប្រព្រឹត្ត របស់អ្នកនៅក្រោមបង្គាប់ តម្រូវឱ្យមានការសួរដេញដោល ប្រសិនបើអ្នកទាំងនោះ "នៅជិត" ជនជាប់ចោទ។ នៅក្នុងករណីដែលភស្តុតាងពាក់ព័ន្ធដោយផ្ទាល់ជាមួយអ្នកនៅក្រោមបង្គាប់ វិធានត្រូវបានបដិសេធជាសកល។ គ្មានករណីយុត្តិសាស្ត្រទាំងប្រាំពីរណាមួយដែលសំអាងដោយសហព្រះរាជអាជ្ញាថា ជាតំណាងករណីយុត្តិសាស្ត្រនៅតុលាការមិនអចិន្ត្រៃយ៍ តុលាការបានទទួលយកជាភស្តុតាងចំនួនពីរលើក ហើយតុលាការ

---

ចម្លើយសាក្សី និងសក្ខីកម្មនៅលើមុខ១ អនុលោមតាមវិធាន៩២ស្ទួន" ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ("សេចក្តីសម្រេច *Blagojevi*") នៅកថាខណ្ឌ១២។

[24] ករណីរដ្ឋអាជ្ញា តទល់ Haradinaj, IT-04-84bis-PT "សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនូវប្រតិចារិតនៃភស្តុតាង ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ស្របតាមវិធាន៩២ស្ទួន" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ (សេចក្តីសម្រេច Haradinaj ") នៅកថាខណ្ឌ២២ (ភស្តុតាងសក្ខីកម្មពីបញ្ហាសំខាន់រវាងភាគី ផ្ទុយពីបញ្ហាខាងក្រៅ ឬបញ្ហាដែលពាក់ព័ន្ធបន្ទាប់បន្សំ តម្រូវឱ្យមានការសួរដេញដោលនៅសវនាការ ។ សេចក្តីសម្រេច *Karadzic* តុលា ២០០៩ នៅកថាខណ្ឌ១០ ។ សេចក្តីសម្រេច Blagojevic នៅកថាខណ្ឌ១២ ("ភស្តុតាងដែលសំខាន់ដល់ការចោទប្រកាន់" តម្រូវឱ្យមានការសួរដេញដោល) ។ ករណីរដ្ឋអាជ្ញា តទល់ *Brdanin*, IT-99-36-T "អត្ថបទដើមសាធារណនៃសេចក្តីសម្រេចសំងាត់ស្តីពីការទទួលយកតាមវិធាន៩២ស្ទួននៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០០២, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០២ ("សេចក្តីសម្រេច *Brdanin*") នៅកថាខណ្ឌ១១ (ភស្តុតាងដែលមានសក្ខីកម្មសំខាន់ដល់ការចោទប្រកាន់ ត្រូវតម្រូវឱ្យមានការសួរដេញដោលនៅសវនាការ)។ សេចក្តីសម្រេច Keremera ថ្ងៃទី១១ ខែធ្នូ ២០០៦ នៅកថាខណ្ឌ ១៦ (ដូចគ្នា)។

[25] ដោយសារ មានការបកស្រាយដូចគ្នាមួយចំនួន ក្នុងការវិភាគវិធាន ៩២ស្ទួន ចំណុច ក និង គ, នៅក្នុងករណីច្បាប់ដែលបាន ដកស្រង់ពីកត្តាទាំងនេះ គឺផ្អែកលើ ការដកចេញនូវសក្ខីកម្ម ដើម្បីបំពេញនូវវត្ថុបំណងរបស់វិធាន ៩២ស្ទួន ចំណុចក ជាជាងចំណុច គ។ ការបែងចែកនេះពុំបង្កវិបាកនៅទីនេះឡើយ ដោយសារ កំណត់ហេតុស្តាប់ចម្លើយ មួយដែល មិនអាចទទួលយកជាភស្តុតាងបានក្រោមវិធាន ៩២ ចំណុច ក គឺ ពិតណាស់ មិនអាចទទួលយកជាភស្តុតាង បានទេបើគ្មាន ការសួរដេញដោលដោយភាគីបដិបក្ខ ក្រោមវិធាន ចំណុច គ។

លើកឡើងយ៉ាងច្បាស់ថាពុំមានភស្តុតាងណាមួយ មានសក្ខីកម្មពាក់ព័ន្ធនឹងអ្នកនៅក្រោមបង្គាប់ឡើយ នៅមុនពេលសម្រេចទទួលយក[26] ហើយនៅពេលតុលាការយល់ឃើញថាការសួរដេញដោលនៅសវនាការ ត្រូវបានតម្រូវដោយសារតែមូលហេតុនោះ[27]។ ជាផលវិបាក ករណីយុត្តិសាស្ត្រត្រូវបានគេចម្លង[28]។

ខ. សក្ខីកម្មទាក់ទងនឹងអំពើ និងការប្រព្រឹត្តនៃសហសមាជិកនៃសហឧក្រិដ្ឋកម្មរួម ដែលនៅជិតជនជាប់ចោទ ត្រូវបានតម្រូវឱ្យមានការសួរដេញនៅសវនាការ[29]។

---

[26] សំណើរដើមរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ ២២(ក) (សំអាងលើសេចក្តីសម្រេច Karadzic តុលា ២០០៩, កថាខណ្ឌ២២(ខ) (សំអាងលើសេចក្តីសម្រេច Blagojevic)។

[27] សំណើរដើមរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២២(ច) (សំអាងសេចក្តីសម្រេច Brdanin)

[28] សេចក្តីសម្រេច *Galic* នៅកថាខណ្ឌ១៤-១៦, សេចក្តីសម្រេច Milosevic មិនា ០២ នៅកថាខណ្ឌ, (អង្គជំនុំជម្រះត្រូវតែប្រុងប្រយ័ត្នខ្ពស់" នៅពេលសម្រេចទទួលយកភស្តុតាង ដោយពុំមានចាំបាច់តម្រូវឱ្យមានការសួរដេញដោលលើភស្តុតាងអំពីអំពើ និងការប្រព្រឹត្តអ្នកនៅក្រោមបង្គាប់ជិតក្បែរ ដែលជនជាប់ចោទអាចទទួលខុសត្រូវពីបទល្មើស)។ ករណី*រដ្ឋអាជ្ញា តទល់ Bagosora*, ICTR-98-41-T "សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីនៅក្រោមវិធាន៩២ស្ទួន ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ២០០៤ ("សេចក្តីសម្រេច *Bagosora* មិនា ០៤") នៅកថាខណ្ឌ ២០-២២, ២៥,២៨ (កំណត់ហេតុដែលមិនផ្តល់សក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ជាប់ចោទ ត្រូវតែតម្រូវឱ្យសួរដេញដោល ដោយសារតែភាពនៅជិតរវាងការប្រព្រឹត្តដែលត្រូវបានពិពណ៌នា និងជនជាប់ចោទ)។ សេចក្តីសម្រេច Brjanin នៅកថាខណ្ឌ១២ (អំពើ និងការប្រព្រឹត្តរបស់អ្នកនៅក្រោមបង្គាប់ និងសហចារីដែលពាក់ព័ន្ធនឹងការសួរដេញដោលនៅសវនាការ) នៅកថាខណ្ឌ២៤-២៦ (សិទ្ធិតទល់យោធាដែលជនជាប់ចោទអាចទទួលខុសត្រូវ), កថាខណ្ឌ៣០ (តម្រូវឱ្យមានការសួរដេញដោលសាក្សីដែលមានសក្ខីកម្មទាក់ទងនឹងទីកន្លែងដែលក្រោមការត្រួតត្រារបស់ជនជាប់ចោទ)។ *Prosecutor v. Hadzihasanovic and Kubura*, IT-01-47-T "សេចក្តីសម្រេចលើបណ្តឹងព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ ស្ទួន (ក) នៃវិធាន" ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៤ (សេចក្តីសម្រេច Hadzihasanovic ថ្ងៃទី០៤ កុម្ភៈ) ទំព័រ ៤ ដល់ ៥។ សេចក្តីសម្រេច Blagojevic នៅកថាខណ្ឌ១២ (ភាពនៅជិតនឹងអំពើ និងការប្រព្រឹត្តដែលបានពិពណ៌នានៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី ទាក់ទងនឹងការប្រើប្រាស់ឆន្ទានុសិទ្ធិពាក់ព័ន្ធនឹងការអនុញ្ញាតឱ្យមានការសួរដេញដោលនៅសវនាការ)។

[29] សេចក្តីសម្រេច *Galic* នៅកថាខណ្ឌ១៣ (ការដែលថាកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីមានសក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់អ្នកនៅក្រោមបង្គាប់" ឬជនដទៃទៀត ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ពីការទទួលខុសត្រូវចំពោះអំពើ និងការប្រព្រឹត្តរបស់ពួកគេ" ដែលពាក់ព័ន្ធនឹងការសម្រេចថា តើត្រូវអនុញ្ញាតឱ្យឱកាសសួរដេញដោលដែរ ឬទេ)។ សេចក្តីសម្រេច Karazic ខែមិនា ០៩ នៅកថាខណ្ឌ៤៤-៤៩ (តម្រូវឱ្យមានឱកាសសួរដេញដេញដោលនៅសវនាការលើសាក្សីដែលផ្តល់

គ. ភស្តុតាងពីទីតាំងបទល្មើស (crime base) ដែលមានសារៈសំខាន់នៅក្រោមកាលៈទេសៈដែលអាចតម្រូវឱ្យមានការសួរដេញដោល បើទោះបីជាវាមិនពាក់ព័ន្ធជាមួយបុគ្គលដែលនៅជិតក្បែរជនជាប់ចោទក៏ដោយ។ ភស្តុតាងបែបនេះមាននៅក្នុងករណីមួយក្នុងចំណោមករណីប្រាំពីរដែលសំអាងដោយសហព្រះរាជអាជ្ញា[30] និងនៅក្នុងករណីជាច្រើនទៀតដែលអាចរកបាននៅក្នុងករណីយុត្តិសាស្ត្រ[31]។

ឃ. ភស្តុតាងបញ្ជាក់ពីរចនាសម្ព័ន្ធរដ្ឋបាល និងបញ្ហា តម្រូវឱ្យមានការសួរដេញដោល បើសិនវាមានសារៈសំខាន់នៅក្រោមកាលៈទេសៈជាច្រើន ឧទាហរណ៍បើសិនជាភស្តុតាងនេះពាក់ព័ន្ធស៊ីជម្រៅដល់ការសម្រេចលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ[32]។

---

សក្ខីកម្មពីអំពី និងការប្រព្រឹត្តរបស់សមាជិកជាន់ខ្ពស់នៃសហឧក្រិដ្ឋរួម ប៉ុន្តែមិនមែនសមាជិកជាន់ទាប ឬថ្នាក់កណ្តាលនៃសហឧក្រិដ្ឋកម្មរួមទេ) ។ រឿងក្តី*រដ្ឋអាជ្ញា តទល់* *Dordevic*, IT-05-87/1-T "សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី K14 ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ស្របតាមវិធាន ៩២ស្ទួន" ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០៩ នៅកថាខណ្ឌ១១-១៧ (ភស្តុតាងកម្រិតទាបនៃឧក្រិដ្ឋកម្មដែលដាក់កំហុសមកលើតែមន្ត្រីថ្នាក់ទាបតម្រូវឱ្យមានការសួរដេញដោលនៅសវនាការ ពីព្រោះជនជាប់ចោទត្រូវបានចោទប្រកាន់ពៅ JCE និងការទទួលខុសត្រូវក្នុងនាមថ្នាក់លើ)។); *Prosecutor v. Stanisic and Zupljanin*, IT-08-91-T "សំអាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់សេចក្តីសម្រេចផ្ទាល់មាត់ ដែលអនុញ្ញាតដោយផ្នែកដល់ញត្តិរបស់ព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកភស្តុតាង ST223 ដោយអនុលោមតាមវិធាន ៩២ ស្ទួន" ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០ (សេចក្តីសម្រេច Stanisic ១០ ធ្នូ), កថាខណ្ឌ ២៦ ដល់ ២៧។

[30] សំណើដើមរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២២(ឆ) (សំអាង*ករណីរដ្ឋអាជ្ញាតទល់ Sikirica*, IT-95-8-T "សេចក្តីសម្រេចលើពាក្យសុំរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនៃប្រចារិតអនុលោមតាមវិធាន៩២ស្ទួន" ចុះថ្ងៃទី២៣ ឧសភាឆ្នាំ២០០១ ។

[31] សេចក្តីសម្រេច Haradinaj នៅកថាខណ្ឌ ៦០, សេចក្តីសម្រេច Milosevic មិនា ០២ នៅថាខណ្ឌ ២៤-២៥, សេចក្តីសម្រេច Milutinovic កក្កដា ០៦ នៅកថាខណ្ឌ១៨ (ភស្តុតាងនៃកន្លែងបទល្មើសមិនជាប់ពាក់ព័ន្ធនឹងអំពើល្មើស និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដែលត្រូវសួរដេញដោល ដោយសារវាត្រូវបានជំទាស់ដោយមេធាវី)។ សេចក្តីសម្រេច Lukic នៅកថាខណ្ឌ២៥ (ត្រូវសួរដេញដេញនៅសវនាការ បើសក្ខីកម្មទាក់ទងនឹងបញ្ហាដែលជនជាប់មិនទទួលខុសត្រូវព្រហ្មណ្ឌដោយផ្ទាល់ ដោយសារតែមានលក្ខណៈសំខាន់គ្រប់គ្រាន់)។សេចក្តីសម្រេច LukicN កថាខណ្ឌ ២៥ (ពាក់ព័ន្ធនឹងសក្ខីកម្មដែលមិនមានការបង្ហាញដោយផ្ទាល់ ចំពោះទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ក្នុងការសួរដេញដោលសាក្សីដោយបដិភាគី ដោយសារតែវាមានសារៈសំខាន់គ្រប់គ្រាន់ហើយ)

[32] រឿងក្តី*រដ្ឋអាជ្ញា តទល់ Oric*, IT-03-68-T, 'សេចក្តីសម្រេចលើសំណើរបស់មេធាវីសុំទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយ Avdo Hesjnovic' ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៥ នៅទំព័រ៣-៤។ សេចក្តីសម្រេច Hadzihasanovic ថ្ងៃទី ០៤ ខែ កុម្ភៈ ទំព័រ ៤ ដល់ ៥។

ង. ភស្តុតាងដែលផ្តល់សក្ខីកម្មអំពីធាតុផ្សំរួម មិនត្រូវបានទទួលយកជាស្វ័យប្រវត្តិដោយគ្មានការសួរដេញដោលឡើយ។ បញ្ហានេះកើតឡើងនៅក្នុងករណីមួយដែលលើកឡើងដោយសហព្រះរាជអាជ្ញា ហើយនៅក្នុងករណីនោះតុលាការទទួលយកភស្តុតាងដែលផ្តល់សក្ខីកម្មពីការវាយប្រហារទ្រង់ទ្រាយធំ និងជាប្រព័ន្ធ ដោយសារតែបញ្ហានោះត្រូវបានពិភាក្សាយ៉ាងទូលំទូលាយនៅតុលាការ និងជាពិសេសសាក្សីជាក់លាក់ទាំងនោះ ត្រូវបានសួរដេញដោលរួចហើយនៅក្នុងការជំនុំជម្រះផ្សេង[33]។ ភស្តុតាងស្រដៀងនេះត្រូវបានបដិសេធមិនទទួលយក បើគ្មានការសួរដេញដោលនៅករណីដទៃទៀតទេ[34]។

## ខ.លក្ខខណ្ឌនៅមុនការទទួលយកភស្តុតាងអនុលោមតាមវិធាន៩២ស្ទួន

១៤. កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលដាក់អនុលោមតាមវិធាន៩២ស្ទួន ត្រូវតែបំពេញបានលក្ខខណ្ឌតម្រូវទូទៅសម្រាប់ការទទួលយកភស្តុតាង រួមទាំងភាពពាក់ព័ន្ធនិងភាពជឿជាក់បាន[35]។ បន្ថែមពីលើនេះសាក្សីត្រូវបានបញ្ជាក់ពីភាពត្រឹមត្រូវរបស់កំណត់ហេតុនៅចំពោះមុខបុគ្គលដែលត្រូវបានអនុញ្ញាតធ្វើជាសាក្សីចំពោះការប្រកាសបែបនេះ ស្របតាមច្បាប់និងនិតីវិធីរបស់រដ្ឋ [ឬ]មន្ត្រីម្នាក់ដែលតែងតាំងដោយរដ្ឋបាលតុលាការសម្រាប់គោលបំណងនេះ”[36]។ កំណត់ហេតុដែលមិនបានត្រួតពិនិត្យដោយបុគ្គលដែលអនុញ្ញាត មិនអាចទទួលយកជាភស្តុតាងបានឡើយ[37]។

---

[33] សំណើដើមរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២២(ង) (សំអាង*រឿងក្តីរដ្ឋអាជ្ញា តទល់* *Naletilic and Martinovic*, IT-98-34-PT, “សេចក្តីសម្រេចទាក់ទងនឹងការជូនដំណឹងរបស់ព្រះរាជអាជ្ញាពីបំណងប្រគល់ប្រតិចារិតនៅក្រោមវិធាន៩២ស្ទួន(ឃ)” ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០១ នៅកថាខណ្ឌ១២)។

[34] រឿងក្តី*រដ្ឋអាជ្ញាតទល់* *Bagosora*, ICTR-98-41-T “សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីស្របតាមវិធាន ៩២ស្ទួន” ចុះថ្ងៃទី ៩ ខែ មិនា ឆ្នាំ ២០០៤ (“សេចក្តីសម្រេច *Bagosara* មិនា ០៤”) នៅកថាខណ្ឌ ៣៨ និងសេចក្តីសម្រេច Karemra ១១ ធ្នូ ០៦ នៅកថាខណ្ឌ២០ ។

[35] សេចក្តីសម្រេចអង្គជំនុំជម្រះនៅកថាខណ្ឌ ២៣ ។

[36] វិធាន ៩២ស្ទួន(ខ) នៃនិតីវិធី និងភស្តុតាងរបស់ ICTY.

[37] ករណី*រដ្ឋអាជ្ញា តទល់* *Bagosara*, ICTR-98-41-T “សេចក្តីសម្រេចលើញត្តិរបស់ Bagosara ទាក់ទងនឹងបញ្ជីឈ្មោះសាក្សី និងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីអនុលោមតាមវិធាន៩២ស្ទួន” ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៦ (“សេចក្តីសម្រេច *Bagosara* ធ្នូ ០៦”) នៅកថាខណ្ឌ៥ ។

### គ.កំណត់ហេតុស្តាប់ចម្លើយសាក្សីមានភស្តុតាងដែលទទួលយកបាន និងភស្តុតាងមិនទទួលយកបាន

១៥. ក្នុងករណីដែលកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលនឹងមិនចូលខ្លួននៅសវនាការ កំណត់ហេតុនេះអាចទទួលយកមួយផ្នែក ហើយមានតែផ្នែកដែលទទួលយកទេ អាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបាន។ អង្គជំនុំជម្រះ"មិនមានឆន្ទានុសិទ្ធិ...ទទួលយកកំណត់ហេតុដែលមិនទទួលយកដែលត្រូវបានគេយល់ថាជាផ្នែកដែលមិនទទួលយក នឹងត្រូវបានគេមិនអើពើ...លក្ខខណ្ឌទទួលយកនឹងបំផ្លាញការវាយតម្លៃបឋមដែលធ្វើឲ្យភាគីទាំងអស់មានមន្ទិលសង្ស័យថា តើផ្នែកណាដែលត្រឹមត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះជាភស្តុតាង ហើយផ្នែកណាដែលមិនត្រឹមត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ ជាភស្តុតាង[38] ហេតុដូច្នេះ អង្គជំនុំជម្រះជាទម្លាប់កោសលុបផ្នែកនៃកំណត់ហេតុដែលមិនអាចទទួលយកជាភស្តុតាងនៅមុនពេលដែលកំណត់នេះអាចទទួលយកជាភស្តុតាង[39]។

១៦. កាតព្វកិច្ចក្នុងការកំណត់អំពីទិដ្ឋភាពនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលត្រូវទទួលយកជាភស្តុតាងអាស្រ័យលើភាគីដែលដាក់កំណត់ហេតុ[40]។ ជាបឋមកាតព្វកិច្ចនេះចេញពីការណ៍ដែលថា ឯកសារត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញា ហើយបន្ថែមពីលើការសន្មតជាមុនថាគ្មានទោសដរាបណាតុលាការមិនទាន់កាត់ទោសជាផ្លូវការ និងបន្ទុកមកលើសហព្រះរាជអាជ្ញាក្នុងការដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវភស្តុតាងដែលអាចទទួលយក ដើម្បីបង្កើតពិរុទ្ធភាពរបស់ជនជាប់ចោទ។ បើគ្មានភាពជាក់

---

[38] ករណី*រដ្ឋអាជ្ញា តទល់* *Bagosara*, ICTR-98-41-T "សេចក្តីសម្រេចលើការទទួលយកជាភស្តុតាងនៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលបានស្លាប់ទៅហើយ" ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ ("សេចក្តីសម្រេច *Bagosara ១៩* មករា ០៥") នៅកថាខណ្ឌ១៧ ។

[39] រឿងក្តី*រដ្ឋអាជ្ញា តទល់* *Prlic*, IT-04-74-T, 'សេចក្តីសម្រេចលើការទទួលយកភស្តុតាងអនុលោមតាមវិធាន៩២ស្ទួន(ក) ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៨ នៅកថាខណ្ឌ១៥ (ព្រះរាជអាជ្ញាត្រូវតែបានកំណត់អត្តសញ្ញាណសម្រង់ដែលពាក់ព័ន្ធ) នៅកថាខណ្ឌ១៦ (បានកោសលុបផ្នែកដែលមិនទទួលយក)។ ករណី*រដ្ឋអាជ្ញាតទល់* *Popovic*, IT-05-88-T "ដីកាលើសារណារបស់ព្រះរាជអាជ្ញាអនុលោមតាមវិធាន៩២ស្ទួន សេចក្តីសម្រេចដែលចេញនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៦" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ ("សេចក្តីសម្រេច *Popovic* ) សម្រេចនៅកថាខណ្ឌ៤-៦ (កោសលុបផ្នែកដែលមិនទទួលយក)។ សេចក្តីសម្រេច Martic នៅកថាខណ្ឌ២៦-២៧ (កោសលុបផ្នែកដែលមិនទទួលយក)។

[40] សេចក្តីសម្រេច Bagosora, មករា ០៥ នៅកថាខណ្ឌ ១៨។

លាក់ចំពោះផ្នែកណានៃកំណត់ហេតុ ត្រូវទទួលយកជាភស្តុតាង ដូច្នេះកំណត់ហេតុទាំងមូលត្រូវតែបដិសេធចោល[41]។

## III. អំណះអំណាង

## ក. សារណាឆ្លើយតបនេះដាក់ទាន់ពេលវេលា

១៧. មេធាវីការពារបានឆ្លើយតបទៅនឹងសំណើដើមរបស់សហព្រះរាជអាជ្ញានៅខែ កក្កដា ឆ្នាំ ២០១១ អនុវត្តតាមពេលវេលាកំណត់ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។ នៅខែ មិថុនា ២០១២ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើសំណើនេះ ដោយបានបដិសេធចោលអំណះអំណាងរបស់មេធាវីការពារក្តីទាក់ទងនឹងភាពមិនអាចអនុវត្តបាននៅ អវតក នៃរបបគតិយុត្តិវិធាន ៩២ស្ទួន និងបានយល់ឃើញជាលើកដំបូងថា ការទទួលយកជាភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយដែលដាក់ដោយសហព្រះរាជអាជ្ញានឹងសម្រេចដោយអនុវត្តរបបគតិយុត្តិនេះ។ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាស្វែងរកការទទួលយកជាភស្តុតាងនៃសក្ខីកម្មជាលាយលក្ខណ៍អក្សរ សមស្របតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ អំណះអំណាងរបស់មេធាវីមានការទាក់ទងនឹងគតិយុត្តិជាក់លាក់នៃវិធាន៩២ស្ទួន បង្ហាញនៅទីនេះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ហើយដូច្នេះសារណាឆ្លើយតបនេះដាក់ទាន់ពេលវេលា[42]។

---

[41] សេចក្តីសម្រេច Bagosora មករា ០៥ នៅកថាខណ្ឌ១៨ (ក្នុងករណីគ្មានការដាក់កំណត់ហេតុ អង្គជំនុំជម្រះមិនអាចបែងចែកផ្នែកនៃកំណត់ហេតុដែលមិនទទួលយក ចេញពីផ្នែកនៃកំណត់ហេតុដែលត្រូវទទួលយកបានទេ។ អាស្រ័យហេតុនេះ កំណត់ហេតុត្រូវតែប្រកាសមិនទទួលយកជាភស្តុតាងបានទេ)។

[42] នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់បញ្ជាក់ ដីការបស់អង្គជំនុំជម្រះនៅក្នុងសេចក្តីសម្រេច របស់ខ្លួនថា បែបបទនៃនីតិវិធី សម្រាប់ការជំទាស់ នៅមិនទាន់បានបង្កើត ហើយ ការជំទាស់នោះ នៅមិនទាន់បានសន្និដ្ឋាននៅឡើយដែរ ។ សូមមើលសារអេឡិកត្រូនិកពី Susan Lamb បញ្ជូនមកភាគីដែលមានកម្មវត្ថុ: សំណើរបស់ កសព E96/7 ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២។ អង្គជំនុំជម្រះបានផ្តល់ ការបញ្ជាក់ តែនៅថ្ងៃ១៩ តុលា ២០១២ ហើយដែលនៅពេលនោះ អង្គជំនុំជម្រះបានដាក់ឱសានវាទ ចំពោះការជំទាស់នេះត្រឹម ថ្ងៃ ២៦ មេសា ២០១៣។ សូមមើលឯកសារ E223/2 , អនុស្សារណ: ពីប្រធានអង្គជំនុំជម្រះសាលាដំបូង ទៅកាន់ភាគី ចេញថ្ងៃទី១៩ តុលា ២០១២ ERN 00852923-00852926, កថាខណ្ឌ ១៤។ នៅពេលនោះ សំណើរបស់ក្រុមការពារក្តី ចំពោះការពង្រីកដែនកំណត់នៃទំព័រ ដែលពាក់ព័ន្ធ នឹង ការឆ្លើយតបបច្ចុប្បន្ន រហូតមកដល់ពេលនេះ មិនទាន់សម្រេចនៅឡើយ ហើយត្រូវដោះស្រាយឡើងវិញត្រឹមថ្ងៃ ៦ វិច្ឆិកា ២០១២ ប៉ុណ្ណោះ។

## ខ. ឯកសារភាគច្រើនមិនអាចទទួលបាន ដោយសារការខកខានរបស់សហព្រះរាជអាជ្ញាក្នុងការញែកឱ្យដាច់ពីគ្នារវាងភស្តុតាងដែលទទួលយកបាន និងភស្តុតាងដែលមិនអាចទទួលបាន

១៨. សហព្រះរាជអាជ្ញាទទួលស្គាល់ថាឯកសាររាប់រយ[43] រួមទាំងភស្តុតាងដែលមានសក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ។ សម្រាប់មូលហេតុខាងក្រោម មេធាវីការពារសូមស្នើឱ្យពិចារណាថា ភស្តុតាងទាំងអស់ រួមទាំងភស្តុតាងដែលមាននៅក្នុងកំណត់ហេតុច្រើនផ្សេងទៀត គឺមិនអាចទទួលយកបានឡើយ។ ឯកសារនីមួយៗក្នុងចំណោមឯកសារទាំងអស់នេះ មិនអាចទទួលយកបាន ឬមិនអាចទទួលយកបានមួយផ្នែក ហើយហេតុដូច្នេះ ត្រូវតែបដិសេធចោលទាំងស្រុង។

១៩. ក្នុងន័យនេះ និងបន្ថែមពីលើករណីយុត្តិសាស្ត្រដែលមិនអាចជំទាស់បាន[44] ការមិនទទួលយកទាំងស្រុងនៃកំណត់ហេតុណាមួយដែលមួយផ្នែកនៃកំណត់នេះមិនអាចទទួលយកបាន គឺជាវិធីសាស្ត្រអនុវត្តតែមួយគត់។ អង្គជំនុំជម្រះមានជម្រើសផ្សេងទៀត (i) បង្ហាញកំណត់ហេតុទាំងស្រុងដោយផ្អែកលើការយល់ឃើញថា មួយផ្នែកនៃកំណត់នេះនឹងត្រូវបានគេមិនយកចិត្តទុកដាក់, (ii) តម្រូវឱ្យសហព្រះរាជអាជ្ញាកំណត់អត្តសញ្ញាណផ្នែកដែលអាចទទួលយក, (iii) តម្រូវឱ្យមេធាវីការពារកំណត់អត្តសញ្ញាណផ្នែកដែលមិនអាចទទួលយក ឬ (iv) ធ្វើការសម្រេចដោយខ្លួនឯង។

២០. ផ្នែកទីមួយ មិនអាចធ្វើបានទេដោយមូលហេតុផ្នែកច្បាប់ និងការអនុវត្ត។ តាមច្បាប់ វិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថាភស្តុតាងដែលមិនអាចទទួលយកបាន មិនអាចដាក់ចំពោះមុខអង្គជំនុំជម្រះបានឡើយ[45]។ ប្រសិនបើអង្គជំនុំជម្រះយល់ថាភស្តុតាងមួយចំនួននៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា មិនអាចទទួលយកបាន អង្គជំនុំជម្រះត្រូវយល់ថាភស្តុតាងបែបនេះមិនអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបានទេ។ តាមការអនុវត្តជាក់ស្តែងភាគីមិនដឹងទេថាតើផ្នែកណានៃកំណត់ហេតុត្រូវទទួលយកជាភស្តុតាង ហើយហេតុដូច្នេះសម្រាប់ជនជាប់ចោទ កំណត់ហេតុនោះគឺជាសារធាតុនៃភស្តុតាងប្រឆាំងនឹងពួកគេ។

---

[43] មានការលំបាកក្នុងការកំណត់អត្តសញ្ញាណច្បាស់លាស់នូវចំនួនកំណត់ហេតុដែលសហព្រះរាជអាជ្ញាយល់ព្រម រួមទាំងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ តែបើពិនិត្យឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា គឺថាចំនួនច្រើនលើសលុប ។

[44] សូមមើលជើងអក្សរលេខ ១៥ ដល់ ១៦ ខាងលើ ។

[45] វិធាន ៨៣(៣)(ឃ) (បើច្បាប់មិនអនុញ្ញាត គឺមិនមែនជាភស្តុតាងដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះឡើយ។

ភាគីនឹងត្រូវធ្វើសេចក្តីសន្និដ្ឋានបិទការជំនុំជម្រះទាំងងងឹតងងុល ទាក់ទងនឹងភស្តុតាងដែលពួកគេយកមកសំអាង និងតម្រូវឱ្យជំទាស់។

២១. ជម្រើសទីបី គឺពិតជាមិនយុត្តិធម៌៖ ជនជាប់ចោទមិនបានស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ១៤០០ នោះទេ ហើយដូច្នេះមិនត្រូវឱ្យទទួលខុសត្រូវចំពោះការវិភាគលើឯកសារទាំងនេះដែរ។ ក្នុងករណីណាក៏ដោយ ការពិនិត្យឯកសារកំណត់ហេតុទាំងនេះមិនអាចធ្វើទៅបានទេ ផ្អែកតាមធនធានដែលមាន និងតម្រូវការនៃការជំនុំជម្រះដែលកំពុងបន្តនេះ[46]។ ហេតុដូច្នេះមានតែលទ្ធភាពមួយគត់គឺថា កំណត់ហេតុត្រូវតែបានបង្ហាញដើម្បីឱ្យរាប់បញ្ចូលជាភស្តុតាងពេញលេញលុះត្រាតែអង្គជំនុំជម្រះ មានបំណងផ្តល់ឱកាសដល់សហព្រះរាជអាជ្ញា ដើម្បីញែកឱ្យដាច់នូវផ្នែកដែលអាចទទួលយកបានចេញពីផ្នែកដែលមិនអាចទទួលយកបាន (ឬការអនុវត្តដោយខ្លួនឯងផ្ទាល់)។

២២. នៅក្នុងដំណាក់កាលនេះ មិនអាចបង្កើតបញ្ជីកំណត់ហេតុស្តាប់ចម្លើយដែលរាប់បញ្ចូលទាំងភស្តុតាងមិនអាចទទួលយកបានទេ។ យ៉ាងហោចណាស់ក៏ការស្តាប់ចម្លើយនោះមានពីរប្រភេទ តែអាចកំណត់បានដោយការសម្រាលសមហេតុផលដោយផ្អែកលើការពិពណ៌នារបស់ព្រះរាជអាជ្ញា ទៅលើសកម្មភាព និងការប្រព្រឹត្តរបស់ជនជាប់ចោទ និងសម្រាប់ហេតុផលដែលនៅបន្ទាប់ពី ស២១ ឬ ស២៤។ កំណត់ហេតុដូចនោះត្រូវតែបដិសេធចោលទាំងស្រុង។ កំណត់ហេតុដែលកំណត់នៅដំណាក់កាលក្រោយអាចតម្រូវឱ្យដកចេញទាំងស្រុង ក្នុងករណីដែលភស្តុតាងមិនទទួលយកមិនត្រូវបានកម្រិតដោយចង្អៀត ឬដោយប្រិតប្រៀនពីកំណត់ហេតុ។ ការជំទាស់ពេញលេញជាងនេះទៅលើកំណត់ហេតុដែលមិនអាចទទួលយកបាននឹងតាក់តែងឡើងនៅមុនកាលកំណត់របស់អង្គជនុំជម្រះនៅខែ មេសា ឆ្នាំ ២០១៣។

[46] សហព្រះរាជអាជ្ញាបានបន្តការអះអាងមិនសមហេតុផលថា ពួកគេមានធនធានប្រហាក់ប្រហែលនឹងក្រុមមេធាវីការពារក្តី។ សូមមើលឯកសារ E-1/123.1 “ប្រតិចារិតសវនាការ” ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១២ ERN 00846635-00846745, p. 40:8-9.។ ការសន្និដ្ឋាននោះ គឺពិតជាមិនអៀនខ្មាស់មែនចំពោះការសន្មតរបស់ខ្លួនថា ជនជាប់ចោទទាំងអស់មិនមែនជាបុគ្គលបីនាក់ផ្សេងគ្នា ដែលមានសិទ្ធិផ្សេងគ្នាក្នុងការបង្ហាញការការពារនោះទេ។ ជាការពិតក្រុមការពារនិមួយៗត្រូវបានតម្រូវឱ្យវិភាគដោយខ្លួនឯង ហេតុដូច្នេះត្រូវធ្វើកិច្ចការបីដងនៃកិច្ចការរបស់សហព្រះរាជអាជ្ញា ដែលមានធនធានមនុស្សតិចជាងការិយាល័យសហព្រះរាជអាជ្ញា។

## គ. ឯកសារកំណត់ហេតុជាច្រើនដែលស្នើឡើងដោយសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ហើយហេតុដូច្នេះមិនអាចទទួលយកជាភស្តុតាងបានទេ

i-ទោះជាសម្រាប់គោលបំណងណាក៏ដោយ ភស្តុតាងពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ មិនអាចទទួលយកបានដែរ

២៣. កំណត់ហេតុស្តាប់ចម្លើយសាក្សីជាច្រើនដែលស្នើដាក់ដោយសហព្រះរាជអាជ្ញា រួមមានទាំងសក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ។ នៅក្នុងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានថ្មីៗនេះដោយមេធាវីការពារក្តី សហព្រះរាជអាជ្ញាបំភ្លឺថា ពួកគេស្វែងរកការទទួលយកភស្តុតាងទាំងនោះ ដើម្បីតែបង្កើត "នយោបាយទូទៅឬរចនាសម្ព័ន្ធ" ជាជាងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទនោះ[47]។

២៤. និតីវិធីដែលស្នើឡើងដោយសហព្រះរាជអាជ្ញា មិនត្រូវបានអនុវត្តនៅតុលាការមិនអចិន្ត្រៃយ៍ណាមួយនោះទេ។ ជាទម្លាប់ភស្តុតាងសក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ជាប់ចោទ ត្រូវបានបដិសេធចោលដោយមិនចាំបាច់ពិចារណាថា តើភស្តុតាងនេះមានសក្ខីកម្មពីអង្គហេតុផ្សេងទៀតដែលពាក់ព័ន្ធនឹងនិតីវិធីដែរឬអត់នោះទេ[48]។ នៅតែជាការពិតដដែលបើទោះបីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទជាពិសេសក្នុងករណីដែល ពួកគេជាមេដឹកនាំជាន់ខ្ពស់ ដែលជាញឹកញយជាករណីនៅតុលាការមិនអចិន្ត្រៃយ៍នានា គឺជាភស្តុតាង ដែលអាចបញ្ជាក់បាននៃអង្គហេតុដទៃទៀត។

២៥. ប្រើឧទាហរណ៍វឹងមាំមួយក្នុងករណីជនជាប់ចោទ ត្រូវចោទប្រកាន់នៅក្រោមទ្រឹស្តីសហឧក្រិដ្ឋកម្មរួមភស្តុតាងពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងគោលបំណងរួមនឹងបញ្ជាក់ពីអត្ថិភាពនៃគោលបំណងរួមដោយជៀសមិនផុត។ ប៉ុន្តែវាត្រូវបានគេបង្កើតយ៉ាងច្បាស់ថា ភស្តុតាងពីគោលបំណងរួមអាច

---

[47] ឯកសារ E-223/1 "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំពិនិត្យឡើងវិញបញ្ជីឈ្មោះភស្តុតាង" ERN 008454445-008454452 នៅកថាខណ្ឌ១២ ។

[48] សេចក្តីសម្រេច Bagosora មករា ០៥ នៅកថាខណ្ឌ ១៧ ("ភស្តុតាងសក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ គឺមិនអាចទទួលបានទេ...ប៉ុន្តែ ផ្នែកផ្សេងៗទៀតនៃកំណត់ហេតុដែលមិនមានសក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទអាចទទួលយក)។ សេចក្តីសម្រេច Brdanin នៅកថាខណ្ឌ ១៤ (សក្ខីកម្មណាមួយទាក់ទងនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ត្រូវបដិសេធជាស្វ័យប្រវត្តិ)។ ករណីរដ្ឋអាជ្ញា តទល់ Karemera, ICTR-98-44-T "សេចក្តីសម្រេចលើញត្តិរបស់ព្រះរាជអាជ្ញាសុំទទួលយកជាភស្តុតាងនៃកំណត់ហេតុរបស់ Joseph Serugendo" ចុះថ្ងៃទី១៥ ខែធ្នូ ២០០៦ ("សេចក្តីសម្រេច Karemera ១៥ ធ្នូ ០៦) នៅថាខណ្ឌ១០ (ភស្តុតាងត្រូវបដិសេធចោល ដោយវាពាក់ព័ន្ធនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ)។

ទទួលយកបាន តែការចូលរួមរបស់ជនជាប់ចោទ ត្រូវបានគេចាត់ទុកថា ជា"អំពើនិងការប្រព្រឹត្ត" ហេតុដូច្នេះភស្តុតាងនេះមិនអាចទទួលយកបានទេ[49]។ ប្រសិនបើទ្រឹស្តីរបស់សហព្រះរាជអាជ្ញាត្រឹមត្រូវ នោះភស្តុតាងពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ អាចត្រូវប្រើប្រាស់សម្រាប់គោលបំណងដទៃទៀតដែលពាក់ព័ន្ធ ហើយកំណត់ហេតុដែលបង្ហាញពីការចូលរួមរបស់ជនជាប់ចោទ នឹងត្រូវទទួលយកជាភស្តុតាង ដើម្បីបង្ហាញពីអត្ថិភាពនៃគោលបំណងរួម។

ii- ភស្តុតាងសក្ខីកម្មពីសេចក្តីសម្រេច ឬការប្រព្រឹត្តរបស់ថ្នាក់ខ្ពស់ រាប់ទាំងគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការ មជ្ឈិម គឺមិនអាចទទួលយកជាភស្តុតាងបញ្ជាក់ពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទបានឡើយ

២៦. អនុលោមតាមដីកាដំណោះស្រាយ បក្សកុម្មុយនីស្ត"ដឹកនាំដោយប្រព័ន្ធដឹកនាំសមូហភាព..អនុវត្តចំពោះប្រព័ន្ធគណៈកម្មាធិការ មានន័យថាសមាជិកមិនអាចធ្វើសេចក្តីសម្រេចដោយខ្លួនឯងបានទេ ប៉ុន្តែជាមួយសមាជិកផ្សេងទៀត[50]។ នៅក្នុងការសួរដេញដោលសាក្សីដោយភាគីបដិបក្ខ សហព្រះរាជអាជ្ញាបានជម្រុញទ្រឹស្តី "ការធ្វើសេចក្តីសម្រេចជាសមូហភាព"[51]។ ហេតុដូច្នេះជាញឹកញយដីកាដំណោះស្រាយទាញការសន្និដ្ឋានអំពីការដឹង ឬការប្រព្រឹត្តរបស់ នួន ជា ពីតួនាទីរបស់គាត់នៅក្នុងគណៈកម្មាធិការផ្សេងៗនៃកម្ពុជាប្រជាធិបតេយ្យ រួមទាំងគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈមជ្ឈិម និងគណៈកម្មាធិការយោធា[52]។ ដីកាដំណោះស្រាយចោទប្រកាន់ដោយសន្មតថា នួន ជា តែងតែទទួលបានសំណៅនៃសារនានាដែលបញ្ជូនទៅ ប៉ុល ពត[53]។

---

[49] សេចក្តីសម្រេច Galic នៅកថាខណ្ឌ១០, សេចក្តីសម្រេច Haradinajនៅកថាខណ្ឌ ៥១ (ភស្តុតាងពីការចូលរួមនៅក្នុងគោលបំណងរួម មិនទទួលយកជាភស្តុតាងឡើយ)។

[50] ឯកសារលេខ **D-427** "ដីកាដំណោះស្រាយ" ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ERN 00604508-00605246 កថាខណ្ឌ ៣៤។

[51] ឧទាហរណ៍សូមមើលឯកសារ E-1/91.1 "ប្រតិចារិតសវនាការ"ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ ERN 00825649-00825790, p. 42:11-25 ។ មើលឯកសារ E-1/92.1 "ប្រតិចារិតសវនាការ"ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ ERN 00826714-00826865, pp. 88:23-89:15 ។

[52] ដីកាដំណោះស្រាយ កថាខណ្ឌ៨៧០, ៨៧៦,៩០១,៩០២, ៩០៥-៩០៦ និង ៩៤៣ ក្នុងចំណោមការយោងជាច្រើនផ្សេងទៀត ។

[53] ដីកាដំណោះស្រាយ កថាខណ្ឌ៧៤។

២៧. កំណត់ហេតុស្តាប់ចម្លើយសាក្សីអាចមានសក្ខីកម្មពី "អំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ" ដោយមិនបានយោងឈ្មោះជនជាប់ចោទ តែកំណត់ហេតុទាំងនេះមានការនិយាយយោងពីអំពើនិងការប្រព្រឹត្តរបស់បុគ្គលនៅក្នុងតួនាទីដែលគាត់ត្រូវបានគេចោទប្រកាន់[54]។ ឧទាហរណ៍ កំណត់ហេតុមានសក្ខីកម្មទាក់ទងនឹងប្រធាន សភាតំណាងប្រជាជន នឹងត្រូវបដិសេធចោលយ៉ាងច្បាស់ ដោយសារកំណត់ហេតុដែលមានសក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ នួន ជា ព្រោះគាត់ត្រូវបានគេចោទប្រកាន់ថាកាប់តួនាទីនោះ។ បើតាមទ្រឹស្តីនៃការធ្វើសេចក្តីសម្រេចជាសមូហភាពដែលសំអាងដោយសហព្រះរាជអាជ្ញា សេចក្តីសម្រេចណាមួយដោយគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម ឬគណៈកម្មាធិការយោធា ត្រូវបានគេយល់ឃើញថាធ្វើឡើងដោយ នួន ជា។ ហេតុនេះ កំណត់ហេតុពាក់ព័ន្ធនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ មិនអាចទទួលយកជាភស្តុតាងបានឡើយបើគ្មានការសួរដេញដោលដោយបដិភាគីក៏ដោយ។ ដូចគ្នានឹងការចោទប្រកាន់ទាក់ទងនឹង "អង្គការ", "៨៧០", "មជ្ឈិមបក្ស", "មេដឹកនាំ", "ក១", "ក៣" ឬក៏ឈ្មោះផ្សេងទៀត ព្រមទាំងព័តមានដែលបានទទួល ឬក៏ការដឹងដែលស្ថិតនៅក្នុងកណ្តាប់ដៃរបស់ ប៉ុល ពត។

## ឃ. ភស្តុតាងពីអង្គហេតុដែល នួន ជា ត្រូវបានចោទថានៅជិតបំផុត គឺមិនអាចទទួលយកបានឡើយ បើគ្មានការសួរដេញដោលនៅសវនាការ

២៨. សក្ខីកម្មណាមួយទាក់ទងនឹងឧក្រិដ្ឋកម្មដែល នួន ជា ត្រូវបានចោទប្រកាន់ថានៅជិតបំផុត គឺមិនអាចទទួលយកបានឡើយ បើគ្មានការសួរដេញដោលនៅសវនាការនោះ រួមទាំង តែមិនកម្រិតចំពោះតែ

---

[54] សេចក្តីសម្រេច Bagosora មិនា ០៤ នៅកថាខណ្ឌ២៥ (បដិសេធចោលភស្តុតាងពីការប្រព្រឹត្តរបស់បុគ្គលិកយោធាដែលគ្មានឈ្មោះ ថាជាអំពើ និងការប្រព្រឹត្តរបស់អ្នកនៅក្រោមបង្គាប់របស់ជនជាប់ចោទជារដ្ឋមន្ត្រីការពារប្រទេស) និងកថាខណ្ឌ៣១ (បដិសេធចោលភស្តុតាងពីអំពើរបស់រដ្ឋមន្ត្រីការពារប្រទេសថាជា ការយោងបញ្ចិតបញ្ចៀងទៅលើជនជាប់ចោទ), សេចក្តីសម្រេច Brdjanin នៅកថាខណ្ឌ១៦ (មិនទទួលយកភស្តុតាងពីទាហានដែលគ្មានឈ្មោះ "ប្រឆាំងនឹងជនជាប់ចោទជាឧត្តមសេនីយ") នៅកថាខណ្ឌ២៤-២៦ (ដូចគ្នា), សេចក្តីសម្រេច Karemera ១៥ ធ្នូ ០៦ នៅកថាខណ្ឌ៩ (យោងទៅលើគណបក្ស MRND", "មេដឹកនាំគណបក្ស MRND, អាជ្ញាធរ MRND និងមន្ត្រីជាន់ខ្ពស់នៃគណបក្ស MRND ជាការយោងចំពោះជនជាប់ចោទដែលមិនអាចទទួលយកបាន)។ សេចក្តីសម្រេច Povic នៅកថាខណ្ឌ៥៧ (យោងចំពោះមន្ត្រីមិនចាំឈ្មោះនៅកិច្ចប្រជុំមួយដែលជនជាប់ចោទត្រូវបានគេសន្មតថាបានចូលរួម មិនអាចទទួលយកជាភស្តុតាង)។

ភស្តុតាងបង្ហាញពីអំពើ និងការប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ដែលជិតស្និទនឹង នួន ជា ឬជនណាដែលគាត់ត្រូវបានចោទប្រកាន់ថាបានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម។ មេធាវីការពារមិនមានលទ្ធភាពបង្កើតបញ្ជីពេញលេញនៃកំណត់ហេតុបែបនេះ ហើយសូមរក្សាសិទ្ធិរបស់ខ្លួនបង្កើតបញ្ជីនេះដោយរង់ចាំការចង្អុលបង្ហាញបន្ថែមពីអង្គជំនុំជម្រះទាក់ទងនឹងសេចក្តីសន្និដ្ឋាននេះ។ តែមេធាវីការពារក្តីបានកំណត់អត្តសញ្ញាណជាបឋមនូវប្រភេទនៃភស្តុតាង ដែលតម្រូវឲ្យបដិសេធចោលដូចខាងក្រោម។

i- ភស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្មនៅស-២១

២៩. ទាំងចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាបានព្យាយាមម្តងហើយម្តងទៀតដើម្បីដាក់ នួន ជា នៅក្នុងតួនាទីដ៏ឧត្តុងឧត្តមទាក់ទងនឹងប្រតិបត្តិការ និងឧក្រិដ្ឋកម្មនៅមន្ទីរស២១។ អនុលោមតាមដីកាដំណោះស្រាយ នួន ជា ទទួលខុសត្រូវរួមលើមន្ទីរស២១[55]ថ្នាក់លើផ្ទាល់របស់ឌុច[56] ធ្វើសេចក្តីសម្រេចបញ្ជូនបុគ្គលិកជាក់លាក់ទៅមន្ទីរស២១[57] ពិនិត្យចម្លើយសារភាពរបស់អ្នកទោសជាក់លាក់[58] បានដឹងពី និងចេញសេចក្តីណែនាំទាក់ទងនឹងការសួរចម្លើយ និងការសម្លាប់អ្នកទោស[59] និងបញ្ជាឲ្យគេសម្លាប់អ្នកទោសក្នុងទ្រង់ទ្រាយធំជាច្រើន[60]។ សហព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ស្រដៀងនេះ[61] ដូចឌុច បានធ្វើនៅក្នុងសក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[62]។

---

[55] ដីកាដំណោះស្រាយ កថាខណ្ឌ ១២៣, ៨៧៧ និង ៩៤៣ ។

[56] ដីកាដំណោះស្រាយ កថាខណ្ឌ ៨៧៨, ៨៧៩ និង ៩២៥ និង៩៤៩-៩៥៧ ។

[57] ដីកាដំណោះស្រាយ កថាខណ្ឌ៤៣៤, ៤៧០, ៩៥៨ - ៩៦២ ។

[58] ដីកាដំណោះស្រាយ កថាខណ្ឌ៩៣០, ៩៣៣, ៩៣៥, ៩៣៦, ៩៤០, ៩៤៤, ៩៦៣ - ៩៦៧ ។

[59] ដីកាដំណោះស្រាយ កថាខណ្ឌ ៩៦៨-៩៧៤ ។

[60] ដីកាដំណោះស្រាយ កថាខណ្ឌ៤៦៧។

[61] សូមមើលឯកសារ D3 ("ដីកាបញ្ជូនរឿងទៅស៊ើបសួរ" ចុះថ្ងៃទី ១៨ ខែ កក្កដា ២០០៧ ERN 00147244-00147399 ,fns 174, 181។

[62] សូមមើលឯកសារ E-1/51.1 ("ប្រតិចារិតសវនាការ" ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០១២ ERN 00792960-00793045, p. 29:17-18 , E-1/52.1 ("ប្រតិចារិតសវនាការ" ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០១២ ERN 00793648-00793757, p. 25:20-23,27:3-8 , E-

៣០. តាមទំនាក់ទំនងតាមការសន្មត ភស្តុតាងនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងរចនាសម្ព័ន្ធរដ្ឋបាលនៅមន្ទីរ ស២១ ច្បាស់ណាស់មិនអាចទទួលយកបានឡើយ។ ជាបឋម ភស្តុតាងណាមួយទាក់ទងនឹងស២១គឺពាក់ព័ន្ធ ឌុច ដោយផ្ទាល់ ឬប្រយោល ហើយដូច្នេះត្រូវបានបដិសេធដោយវិធានដាច់ខាត ទាក់ទងនឹងជនជាប់ចោទ និងអ្នកនៅក្រោមបង្គាប់ផ្ទាល់របស់គាត់[63]។ នៅក្នុងករណីនេះវិធាននោះ គឺមានលក្ខណៈសំខាន់ធំធេង ពីព្រោះ ឌុច មិនត្រឹមតែជាអ្នកនៅក្រោមបង្គាប់ នួន ជា ទេតែ ឌុច ជាសាក្សីសំខាន់តែមួយគត់ប្រឆាំងនឹង នួន ជា។ ភស្តុតាងដែលបញ្ជាក់ពីតួនាទី និងការប្រព្រឹត្តរបស់ ឌុច នៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងភាពអាចជឿជាក់បានរបស់គាត់ គឺជាការសំខាន់ដែលត្រូវតែសួរដេញដោល។ ទីពីរ តួនាទីតាមការសន្មតរបស់ នួន ជា និងការគ្រប់គ្រងរបស់គាត់នៅស២១ គឺជាភស្តុតាងផ្ទាល់ និងជាភស្តុតាងសំខាន់ ដែលត្រូវតែបានចាត់ទុកថានៅជិតក្បែរបញ្ហាអ្វីមួយដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទីនោះ(ស២១)។ នៅតុលាការមិនអចិន្ត្រៃយ៍ តុលាការតែងតែបដិសេធភស្តុតាងទីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋដែលនៅឆ្ងាយពីកាលៈទេសៈ[64]។ ទាំងនេះបង្កើតបានជាទឡ្ហីករណ៍ច្បាស់ និងមិនចំណុះសម្រាប់ការបដិសេធនេះហើយមួយណាក៏គ្រប់គ្រាន់ដែរ។

ii. <u>ភស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្មនៅមន្ទីរស-២៤</u>

៣១. ដីកាដំណោះស្រាយបានលើកឡើងថា ស២៤ គឺជា “ផ្នែកមួយរបស់” ស២១ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ឌុច និងថា នួន ជា ក៏ជា “អ្នកទទួលខុសត្រូវ” និងធ្វើការសម្រេចជាក់លាក់ក្នុងការបញ្ជូនអ្នកជាប់ឃុំមកកាន់ទីនោះ[65]។ សម្រាប់ហេតុផលដែលបានលើកឡើងរួចមកហើយពីខាងលើ[66]

---

1/53.1 (“ប្រតិចារិតសវនាការ” ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១២, ERN 00795037-00795152 p.56:17-25, E-1/54.1 (“ប្រតិចារិតសវនាការ” ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១២ ERN 00795565-00795675, pp. 28:6-11, 31:3-16, 48:9-52:13 ។

[63] សូមមើលនៅ ១៣ (ក)ខាងលើ ។

[64] សូមមើលសេចក្ដីសម្រេច Bagosora មិនា ០៤ នៅកថាខណ្ឌ២៥ (គ្រាន់តែនិយាយយោងទៅលើអំពីរបស់បុគ្គលិកយោធា ត្រូវតម្រូវឲ្យមានការសួរដេញដោលដោយជនជាប់ចោទដែលជាមន្ត្រីយោធាជាន់ខ្ពស់)។ សេចក្ដីសម្រេច Brdanin នៅកថាខណ្ឌ១៦ (ប្រហាក់ប្រហែលគ្នា)។

[65] ដីកាដំណោះស្រាយ, កថាខណ្ឌ៤០២,៨៧៧,៩៥៩។

[66] សូមមើលកថាខណ្ឌ ២៩ ដល់៣០, ដូចខាងលើ។

ឧក្រិដ្ឋកម្មដែលចោទថាបានប្រព្រឹត្តនៅ ស២៤ និងរចនាសម្ព័ន្ធរដ្ឋបាលនៅទីនោះ គឺនៅជិតផ្ទាល់នឹង នួន ជា ខ្លាំងណាស់ ដូច្នេះ វាចាំបាច់ត្រូវតែធ្វើការសួរដេញដោលដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃការទទួលយកជាភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី។

iii. <u>រចនាសម្ព័ន្ធរដ្ឋបាល និងការទំនាក់ទំនង</u>

៣២. ករណី០០២/០១ ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២។ ទោះបីជាដីកាដំណោះស្រាយបានបង្ហាញភស្តុតាងមួយចំនួនទាក់ទងនឹងតួនាទីរបស់ នួន ជា ក្នុងការផ្តួចផ្តើមបង្កើតឱ្យមានគោលនយោបាយផ្លាស់ទីលំនៅប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយក៏ ឧក្រិដ្ឋកម្មដែលចោទប្រកាន់ក្នុងសំណុំរឿង០០២/០១ គឺហួសឆ្ងាយពីការជម្លៀសប្រជាជនដោយបង្ខំ ព្រោះ នួន ជា ត្រូវបានចោទប្រកាន់ឱ្យទទួលខុសត្រូវពីឧក្រិដ្ឋកម្មជាច្រើនដែលបានប្រព្រឹត្តអំឡុងពេលផ្លាស់ទីលំនៅ ប្រជាជន ដែលរួមមានទាំងការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ ការទទួលខុសត្រូវជាបុគ្គលរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មទាំងនោះ គឺមួយភាគធំផ្អែកទៅលើការចេញបញ្ជា ការញុះញង់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម និងការត្រួតត្រាកម្មាភិបាលខ្មែរក្រហមថ្នាក់ទាបដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ[67]។

៣៣. ទម្រង់នៃការទទួលខុសត្រូវទាំងនោះសន្មតទុកជាមុនអំពីអត្ថិភាពនៃខ្សែសង្វាក់បញ្ជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានមេធាវីការពារក្តីជំទាស់យ៉ាងខ្លាំង។ អ្នកជំនាញនាំមុខរបស់ពិភពលោកជាច្រើននាក់ដែលរួមទាំងលោក David Chandler, Stephen Heder និងលោក Michael Vickery ក្នុងចំណោមអ្នកដទៃទៀត យល់ស្របថា ប្រហែលជាការសម្លាប់ភាគច្រើនត្រូវបានធ្វើឡើងដោយអាជ្ញាធរមូលដ្ឋាន និងតំបន់ ដែលអនុវត្តផ្ទុយពីខ្សែសង្វាក់នៃការបញ្ជាយ៉ាងតឹងរឹងពីថ្នាក់លើ ដែលជារចនាសម្ព័ន្ធឋានានុក្រមធូររលុង និងច្របូកច្របល់... កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមទាំងនោះ *មិន "ត្រឹមតែធ្វើតាមបញ្ជាឡើយ"*។ តាមការអនុវត្តន៍ជាក់ស្តែង កម្រិតសំខាន់បំផុតនៃខ្សែសង្វាក់បញ្ជា និង

---

[67] ដីកាដំណោះស្រាយ, កថាខណ្ឌ១៥៤៤ ដល់ ១៥៤៥ (ការរៀបចំផែនការ), កថាខណ្ឌ ១៥៤៧ ដល់១៥៤៨១៥៥៧-១៥៥៩ (ការញុះញង់) (ការទទួលខុសត្រូវរបស់ថ្នាក់លើដែលត្រូវបានគេសន្មត់ថាបានគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពលើអ្នកនៅក្រោមបង្គាប់)។

ឋានានុក្រមនៃអំណាច និងអំណាចប្រតិភូកម្ម គឺធ្លាក់ទៅលើថ្នាក់ស្រុកដោយធ្វើឱ្យលេខាស្រុករបស់បក្សក្លាយជាឥស្សរៈជនសំខាន់ក្នុងការទទួលខុសត្រូវលើការសម្លាប់ប្រជាជនទូទាំងប្រទេស[68]។

៣៤. ដូច្នេះ លក្ខណៈនៃឋានានុក្រមដែលបានភ្ជាប់ នួន ជា ទៅនឹងបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងនោះដោយផ្ទាល់ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ហើយវានៅតែ ជា"បញ្ហាដ៏គួរឱ្យចាប់អារម្មណ៍បំផុត" ក្នុងសំណុំរឿង០០២/០០១[69]។ ភស្តុតាងពាក់ព័ន្ធទៅនឹងឋានានុក្រម ត្រូវតែយកមកសួរដេញដោល ជាពិសេសចំពោះភស្តុតាងណាដែលចេញពីកម្មាភិបាលថ្នាក់ក្រោមដែលមានចេតនាច្បាស់លាស់ដើម្បីទម្លាក់ការទទួលខុសត្រូវទៅថ្នាក់លើ ហើយចាត់ទុកខ្លួនឯងគ្រាន់តែជាបរិវាដែលគ្មានអំណាច ហើយគ្មានចេតនាសម្លាប់មនុស្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សក្ខីកម្មបែបនេះ គឺពិតជាមិនអាចជឿជាក់បានឡើយ ហើយក៏មិនអាចទទួលយកជាភស្តុតាងដែលមានតម្លៃបានដែរ។

៣៥. ភស្តុតាងពាក់ព័ន្ធនានានឹងរចនាសម្ព័ន្ធរដ្ឋបាល និងការទំនាក់ទំនងដែលពាក់ព័ន្ធនឹង "មន្ទីរ" ដូចដែលត្រូវបានលើកឡើងជាទូទៅក្នុងដីកាដំណោះស្រាយ រួមមាន "អង្គការ", "មន្ទីរ៨៧០", ក១, ក៣, គណៈមជ្ឈិម, គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការយោធា ព្រមទាំងភូមិភាគ ដែលត្រូវបានចោទប្រកាន់ថាបានទាក់ទងដោយផ្ទាល់ជាមួយមជ្ឈិម គឺមិនអាចទទួលយកបានទេ ប្រសិនបើ គ្មានការសួរដេញដោល[70]។

iv. <u>អំពើ និងការប្រព្រឹត្តរបស់សមាជិកនៃសហឧក្រិដ្ឋកម្មរួម</u>

---

[68] ឯកសារ E-190.1.398 (ការវាយតម្លៃឡើងវិញអំពីតួនាទីរបស់មេដឹកនាំជាន់ខ្ពស់ និងមន្ត្រីមូលដ្ឋានក្នុងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ: ការទទួលខុសត្រូវរបស់កម្ពុជាក្នុងទស្សនវិស័យប្រៀបធៀប) ឯកសារ ERN 00661455-00661491, ទំព័រទី១២, ឯកសារ **E-1/94.1**, "ប្រតិចារិក នៃដំណើរការជំនុំជម្រះ", ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២, ឯកសារ ERN 00829800-00829959, pp. 65:5-68:8; ឯកសារ **D-222/1.17**, "កម្ពុជា ពីឆ្នាំ១៩៧៥ ដល់១៩៨២", ឯកសារ ERN 00396894-00397284, ទំព័រ៧៣-៧៤(ពិពណ៌នាអំពីការអនុវត្ត និងស្ថានភាពខុសប្លែកគ្នាខ្លាំងបំផុតទូទាំងស្រុក និងភូមិ) ,ទំព័រ៧១-១៤៨(ហួសពីទូទៅ)។

[69] សូមមើលកថាខណ្ឌ ១២ ដូចខាងលើ។

[70] មេធាវីការពារក្តីមិនយល់ឃើញថាភស្តុតាង*ណាក៏ដោយ* ដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងត្រូវតែយកមកសួរដេញដោលឡើយ ជាពិសេសភស្តុតាងពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៅកម្រិតក្រោមថ្នាក់តំបន់។

៣៦. នួន ជា ត្រូវបានចោទប្រកាន់ថាបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមជាមួយនឹងសមាជិកជាច្រើនទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមានសមាជិកគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ថ្នាក់ដឹកនាំនៃក្រសួងនានារបស់បក្សកុម្មុយនីស្តកម្ពុជា,... លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត និងថ្នាក់ដឹកនាំនៃកងពលមជ្ឈិមបក្ស[71]។ បុគ្គលនីមួយៗទាំងនេះត្រូវបានចោទប្រកាន់ថាបានបំពេញការងារយ៉ាងជិតស្និតបំផុតជាមួយ នួន ជា ដូច្នេះកំណត់ហេតុស្ដាប់ចម្លើយរបស់ពួកគេមិនអាចទទួលយកបានទេ ប្រសិនបើគ្មានការសួរដេញដោល ។

ក. ដោយសារតែទ្រឹស្ដីនៃការធ្វើសេចក្ដីសម្រេចជាសមូហភាពដូចដែលបានលើកមកបង្ហាញក្នុងដីកាដំណោះស្រាយ អំពើ និងការប្រព្រឹត្តរបស់សមាជិកដទៃទៀតនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ គឺមានទំនាក់ទំនងយ៉ាងជិតស្និតបំផុតជាមួយជនជាប់ចោទ[72]។

ខ. លេខាភូមិភាគ និងលេខាតំបន់ស្វយ័តត្រូវបានចោទប្រកាន់ថាបានទទួលបញ្ជាពីមេដឹកនាំមួយចំនួនតូចនៅមជ្ឈិមបក្ស និងរាយការណ៍ជាប្រចាំដោយផ្ទាល់ទៅក្រុមមេដឹកនាំនោះជាពិសេសរាយការណ៍ទៅ នួន ជា[73] ដែលត្រូវបានគេចោទប្រកាន់ថាបានតែងតាំងបុគ្គលទាំងនោះជាច្រើនរូបដោយផ្ទាល់នៅពេលដែលគាត់មានតួនាទីជាប្រធានគណៈចាត់តាំងមជ្ឈិមបក្ស[74]។ ជាងនេះទៅទៀត លក្ខណៈឋានានុក្រម គឺជាធាតុផ្សំដ៏សំខាន់នៃករណីចោទប្រកាន់ ហើយវាជាបញ្ហាដែលមេធាវីការពារក្ដីធ្វើការជំទាស់យ៉ាងខ្លាំងបំផុត[75]។

គ. នួន ជា ត្រូវបានចោទប្រកាន់ថាជាសមាជិកនៃគណៈកម្មាធិការយោធា ហើយជាអ្នកទទួលខុសត្រូវ និងបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការយោធានិងសន្តិសុខ[76]។ គាត់ត្រូវបានចោទប្រកាន់ថាបានជួប និងធ្វើការជារៀងរាល់ថ្ងៃជាមួយ សុន សេន ដែលទទួលខុសត្រូវដោយផ្ទាល់លើកងពលមជ្ឈិម[77]។

---

[71] ដីកាដំណោះស្រាយ, កថាខណ្ឌ១៥៩។

[72] សូមមើលកថាខណ្ឌ ២៦ ខាងលើ។

[73] ដីកាដំណោះស្រាយ, កថាខណ្ឌ៨៦, ៧១,៧៦ដល់៧៧,៨១,៨៧២,៨៨៦,៩១១,៩៣០ដល់៩៣១។

[74] ដីកាដំណោះស្រាយ, កថាខណ្ឌ៨៨០។

[75] សូមមើលកថាខណ្ឌ ៣២ ដល់ ៣៤, ដូចជើងទំព័រខាងលើ។

[76] ដីកាដំណោះស្រាយ, កថាខណ្ឌ៨៧៣ដល់៨៧៥។

[77] ដីកាដំណោះស្រាយ, កថាខណ្ឌ ៨៧៥។

ឃ. នួន ជា ត្រូវបានគេចោទថាជាអ្នកទទួលខុសត្រូវ សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ[78]។ ដីកាដំណោះស្រាយបញ្ជាក់ថាថ្នាក់ដឹកនាំនៃក្រសួងនីមួយៗបានរាយការណ៍ ដោយផ្ទាល់ទៅកាន់ នួន ជា ហើយដីកាដំណោះស្រាយបានផ្ដល់ឧទាហរណ៍ជាក់លាក់អំពីទំនាក់ទំនងបែបនេះ[79]។

## ង. ភស្តុតាងបញ្ជាក់ពីទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មហួសពីវិសាលភាពនៃសំណុំរឿង០០២/០១ដែលអាចទទួលយកបានគឺត្រូវយកមកប្រើសម្រាប់តែគោលបំណងមួយដែលមានដែនកំណត់តែប៉ុណ្ណោះ

៣៧. កំណត់ហេតុស្ដាប់ចម្លើយជាច្រើននៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា គឺពាក់ព័ន្ធនឹងភស្តុតាងដែលបញ្ជាក់ពីទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មហួសពីវិសាលភាពនៃសំណុំរឿង០០២/០១។ សហព្រះរាជអាជ្ញាលើកឡើងថា កំណត់ហេតុស្ដាប់ចម្លើយទាំងនេះគឺពាក់ព័ន្ធទៅនឹងអត្ថិភាពនៃគោលនយោបាយសហឧក្រិដ្ឋកម្មរួម និងការវាយប្រហារជាប្រព័ន្ធគ្រប់ទីកន្លែងប្រឆាំងជនស៊ីវិលដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[80]។

៣៨. ទោះបីជាភស្តុតាងទាំងនេះមួយចំនួនទំនងជាអាចទទួលយកបាន ដោយគ្មានការសួរដេញដោលក៏ដោយក៏គោលបំណងនៃការប្រើប្រាស់ភស្តុតាងទាំងនេះត្រូវតែមានកម្រិតតូចចង្អៀតបំផុតដែរ ដើម្បីបញ្ជាក់ពីអត្ថិភាពនៃការវាយប្រហារជាប្រព័ន្ធ និងគ្រប់ទីកន្លែង។ ភស្តុតាងបែបនេះមិនអាចត្រូវបានគេប្រើប្រាស់រួមគ្នាដើម្បីបញ្ជាក់ពីការដឹងឮ ឬចេតនារបស់ជនជាប់ចោទដែលមាននៅក្នុងការប្រព្រឹត្ត និងអកប្បកិរិយារបស់ជនជាប់ចោទរួចហើយនោះទេ ដូច្នេះវាមិនអាចទទួលយកបានទេ អនុលោមតាមវិធាន៩២*ស្ទួន* ។

៣៩. យោងតាមសហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូល ICTY ក្នុងរឿងក្ដី Galic យល់ឃើញថាភស្តុតាងជាលាយលក្ខណ៍អក្សរបញ្ជាក់ពីទីកន្លែងប្រព្រឹត្តឧក្រិដ្ឋ អាចត្រូវបានគេប្រើប្រាស់ដើម្បីបង្ហាញ

---

[78] ដីកាដំណោះស្រាយ, កថាខណ្ឌ៨៨១, ៩៤៥។

[79] ដីកាដំណោះស្រាយ, កថាខណ្ឌ១២១4, ១២១៧។

[80] សំណើបន្ថែមទៀតរបស់ កសព, កថាខណ្ឌ១២។

ពីគំរូនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម និងថាជនជាប់ចោទ*ប្រាកដជា* បានដឹងថាទង្វើរបស់គាត់ (ដែលបញ្ជាក់ដោយភស្តុតាងផ្ទាល់មាត់) ស៊ីសង្វាក់គ្នាទៅនឹងគំរូនោះ[81]។ ប៉ុន្តែ អង្គជំនុំជម្រះក្នុងរឿងក្តី Galic បានចាត់ទុកកំណត់ហេតុនៃការស្តាប់ចម្លើយបែបនេះជាផ្នែកមួយនៃការវិភាគរបស់ខ្លួនតាមវិធាន៩២*ស្ទួន* (ក) លើការសន្មតទុកជាមុនថា សាក្សីត្រូវតែមានវត្តមានដើម្បីសួរដេញដោល។ ទើបតែពីរកថាខណ្ឌខាងក្រោយមកទៀតប៉ុណ្ណោះ ទើបតុលាការនេះចាត់ទុកថា បទដ្ឋានបែបនេះអាចយកមកអនុវត្តចំពោះការទទួលយកជាភស្តុតាងដោយមិនចាំបាច់មានការសួរដេញដោល ប៉ុន្តែនៅត្រង់ចំណុចនេះតុលាការបានព្រមាន*យ៉ាងច្បាស់ប្រទាំងនឹង*ការនិយាយយោងទៅរកការដឹងឮរបស់ជនជាប់ចោទចេញពីភស្តុតាងនៃការប្រព្រឹត្តឧក្រិដ្ឋកម្មគ្រប់ទីកន្លែងដោយអ្នកនៅក្រោមបង្គាប់[82]។ ដោយសារហេតុផលនេះ តុលាការដទៃទៀតតម្រូវឱ្យមានការសួរដេញដោលទាក់ទងនឹងភស្តុតាងបែបនេះ[83]។

## ច. សក្ខីកម្មជាលាយលក្ខណ៍អក្សរភាគច្រើនដែលដាក់ដោយសហព្រះរាជអាជ្ញា ខកខានមិនបានបំពេញលក្ខខណ្ឌតម្រូវផ្លូវការរបស់វិធាន៩២ *ស្ទួន* (ខ) ។

i. <u>ការសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា</u>

៤០. បើតាមមេធាវីការពារក្តីបានដឹង គ្មានការស្តាប់ចម្លើយណាមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានយកមកផ្ទៀងផ្ទាត់តាមវិធីណាមួយដោយអាជ្ញាធរនៅក្រោមអំណាចរបស់ អវតក

---

[81] សំណើបន្ថែមទៀតរបស់ កសត, កថាខណ្ឌ១៦។

[82] សេចក្តីសម្រេចក្នុងរឿងក្តី Galic, កថាខណ្ឌ១៤។

[83] សេចក្តីសម្រេច Bagosoraមិនា ០៤ នៅកថាខណ្ឌ៣៨ ("ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅទីនេះទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មទ្រង់ទ្រាយធំដោយអ្នកនៅក្រោមបង្គាប់របស់ជនជាប់ចោទ ដូច្នេះគេអាចវែកញែកបានថាជនជាប់ចោទគួរតែបានដឹងអំពីការប្រព្រឹត្តរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួន។ ក្នុងករណីនេះ លក្ខខណ្ឌតម្រូវនៃការជំនុំជម្រះដោយយុត្តិធម៌តម្រូវឱ្យមានការទទួលយកជាភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយដោយមានការសួរដេញដោល")។ សេចក្តីសម្រេច Karemera ១១ ធ្នូ ០៦ កថាខណ្ឌទី២០ ("ភស្តុតាងនឹងត្រូវបានគេប្រើដើម្បីបញ្ជាក់ថាការរំលោភផ្លូវភេទពិតជាបានប្រព្រឹត្តជាប្រព័ន្ធនឹងគ្រប់ទិសទីដោយអ្នក នៅក្រោមបង្គាប់របស់ជនជាប់ចោទ និង/ឬសហចារី។ ការចោទប្រកាន់ទាំងនេះគឺមានសារៈសំខាន់ណាស់ចំពោះករណីរបស់រដ្ឋអាជ្ញារហូតដល់វាក្លាយជារឿងមិនយុត្តិធម៌ចំពោះជនជាប់ចោទក្នុងការទទួលយកភស្តុតាងជាលាយលក្ខណ៍អក្សរ ដោយមិនមានឱកាសតទល់សាក្សី") ។

ឬក្រោមអំណាចអាជ្ញាធរកម្ពុជាឡើយ។ ដូច្នេះ ការស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានបំពេញលក្ខខណ្ឌតម្រូវក្រោមវិធាន៩២ស្ទួន(ខ) ដែលចែងថា កំណត់ហេតុដែលត្រូវទទួលយកត្រូវតែមានការបញ្ជាក់អះអាងពីសាក្សី ហើយត្រូវបានចុះហត្ថលេខាដោយមានវត្តមានអាជ្ញាធរមួយក្នុងចំណោមអាជ្ញាធរទាំងពីរ។ ដូច្នេះការស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលនេះមិនអាចទទួលយកបានឡើយ[84]។

៤១. វិធាន៩២ស្ទួន(ខ) មិនគួរត្រូវបានគេបដិសេធចោលថាជាទម្រង់នៃលក្ខខណ្ឌតម្រូវតែមួយគត់ឡើយ។ គោលបំណងនៃវិធាននេះ គឺដើម្បីធានាថាវាត្រូវតែមានការពិនិត្យមើលខ្លះទៅលើកំណត់ហេតុដែលបានផ្តល់ឱ្យភាគីទី៣ ដោយគ្មាននរណាម្នាក់ពាក់ព័ន្ធនឹងតុលាការនោះចូលមករៀបចំចាត់ចែងឱ្យមានការទទួលកំណត់ហេតុនោះជាភស្តុតាង *ដោយគ្មានឱកាសធ្វើការសួរដេញដោល* នោះឡើយ។ អនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់សក្ខីកម្មថាមជ្ឈមណ្ឌលរបស់ខ្លួន គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលឯករាជ្យមួយ។ នេះគឺជាការសន្និដ្ឋានមួយដែលប៉ះពាល់ដល់ការទទួលយកកំណត់ហេតុ អនុលោមតាមវិធាន៩២ *ស្ទួន*[85]។

៤២. ក្តីបារម្ភទាំងនោះត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងៗដោយសារតែគោលដៅស្ថាប័នមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលរួមមានការចងក្រងភស្តុតាងដើម្បីប្រើក្នុងការចោទប្រកាន់អ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ កម្រងសំណួរដែលអ្នកសម្ភាសន៍របស់មជ្ឈមណ្ឌលនេះប្រើ ត្រូវបានចែកជាប្រភេទឧក្រិដ្ឋកម្មអន្តរជាតិជាក់លាក់ជាច្រើន ដោយស្វែងរកភស្តុតាងពាក់ព័ន្ធនានាដើម្បីបង្កើតបានជាធាតុផ្សំឧក្រិដ្ឋកម្មនីមួយៗ[86]។ យោងតាមអនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ព័ត៌មានដែលប្រមូលបានតាមរយៈកម្រងសំណួរនោះ មិនមែនត្រឹមតែសម្រាប់គោលបំណងប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់អ្នកដែលចង់ស្វែងរកយុត្តិធម៌ឱ្យជនដែលនៅរស់

---

[84] សូមមើលកថាខណ្ឌ១៤ ខាងលើ។

[85] ឯកសារ **E-1/31.1**, "ប្រតិចារិកនៃសវនាការ", ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២, ERN 00772575-00772677, pp. 6:20-8:7, 24:1-16។

[86] ឯកសារ **E-3/158**, 'Guide for Historical Interviews', ថ្ងៃទី ៤ ខែ មិនា ឆ្នាំ ២០១១, ERN 00291445-00291464។

រានមានជីវិតពីរបបខ្មែរក្រហមផងដែរ[87]។ លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាបាន យល់ស្របថា គោលបំណងនៃការសម្ភាសន៍របស់មជ្ឈមណ្ឌល គឺដើម្បីប្រមូលព័ត៌មានប្រវត្តិសាស្ត្រ ដើម្បីឲ្យតុលាការអាចស្វែងរកពិរុទ្ធជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[88]។

៤៣. គេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានពន្យល់ថាគម្រោង Accoutability Project មិនគ្រាន់តែដើម្បីស្វែងរកបុគ្គលទទួលខុសត្រូវទូទៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្ដោតជាពិសេសទៅលើ នួន ជា និងសហចារីរបស់គាត់ ដោយលើកឡើងថាគម្រោងនេះគឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងរឿងក្ដីប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិតនៅ អវតក[89]។ លោក ឆាំង យុបានយល់ស្របថាគាត់បានតទល់ជាសាធារណៈ ប្រឆាំងនឹងនួនជា។[90] អនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាបានលើក ឡើងថា មជ្ឈមណ្ឌលបានរក្សាឯកសារដែលពាក់ព័ន្ធនឹងចុងចោទនីមួយៗដែលកំពុងស្ថិតក្នុងការជំនុំ ជម្រះក្នុងសំណុំរឿង០០២[91]។

៤៤. នៅក្នុងករណីនេះអ្វីដែលជាក្ដីបារម្ភបំផុតនោះ គឺការទទួលស្គាល់ដោយស្មោះរបស់លោកឆាំងថា នៅក្នុងការសម្ភាសន៍មជ្ឈមណ្ឌល DC-Cam "មិនបានធ្វើតាម"ការស្នើឡើងថា ការសម្លាប់ជាច្រើនត្រូវបានប្រព្រឹត្តដោយកម្មាភិបាលជាន់ទាប ដោយមិនមានការណែនាំពីថ្នាក់ដឹកនាំនៅមជ្ឈិមឡើយ[92]។ តាមពិតលោក ឆាំង កត់សម្គាល់ថា ក្នុងចំណោមប្រជាជនជាង ១ ០០០ នាក់ដែលត្រូវបានសម្ភាសន៍ ពុំមានពួកគេណាម្នាក់សារភាពថាបានប្រព្រឹត្ត ឬជាប់ពាក់ព័ន្ធនឹងអំពើព្រហ្មទណ្ឌណាមួយឡើយ ហើយដោយផ្អែកលើមូលដ្ឋាននោះគាត់សន្និដ្ឋានដោយមិនសមហេតុសមផលថា "ពុំមានមនុស្សណាម្នាក់ក្នុងចំណោមពួកគេ ប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះ ឬធ្លាប់បានសម្លាប់មនុស្សណាម្នាក់ឡើយ"[93]។ បើពិចារណា

---

[87] ឯកសារ **E-1/32.1**, "ប្រតិចារិកនៃសវនាការ"ថ្ងៃទី ២៤ មករា ឆ្នាំ ២០១១, ERN 00773146-00773267, p. 86:2-4 ។

[88] ឯកសារលេខ. **E/38.1** "ប្រតិចារិកនៃសវនាការ" ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២, ERN 00777033-00777149, p. 87:14-16។

[89] ឯកសារលេខ **E-1/32.1**"ប្រតិចារិកនៃនីតិវិធីជំនុំជម្រះ" ថ្ងៃទី ២៤ មករា ឆ្នាំ ២០១២, ERN 00773146-00773267, p. 80:19-25.

[90] ឯកសារលេខ **E1/38.1** "ប្រតិចារិកនៃនីតិវិធីជំនុំជម្រះ"ថ្ងៃ ២ កុម្ភៈ ២០១២ , ERN 00777033-00777149, p 78:8-24

[91] ឯកសារលេខ **E-1/33.1**, (ប្រតិចារិកនៃនីតិវិធីជំនុំជម្រះ) , ចុះថ្ងៃទី ២៥ មករា ២០១២ ERN 00774031-00774129, ទំព័រ 1:16-3:19

[92] ឯកសារ **E-1/39.1**, 'ប្រតិចារិត សវនាការ" ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ERN 00778068-00778180, p. 77:5-13 ។

[93] ឯកសារ **E-1/39.1**, ប្រតិចារិត សវនាការ" ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ERN 00778068-00778180, p. 77:5-13. ។

ពីភាពមិនអាចកើតឡើងនៅក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ សក្ខីកម្មរបស់លោក ឆាំង គឺដូចគ្នានឹងការទទួលស្គាល់ថា វិធីសាស្ត្ររបស់អ្នកសម្ភាសន៍នៃមជ្ឈមណ្ឌល DC-Cam និងការសម្ភាសន៍ដែលធ្វើឡើងដោយពួកគេ គឺលំអៀងអ្នកកាន់លទ្ធិ 'manichean'[94]។ ការបរិយាយនៃការទទួលខុសត្រូវថ្នាក់លើ ការលំអៀងបែបនោះវាយប្រហារចំនុចស្នូលរបស់បញ្ហានៅក្នុងករណី០០២៖ តើឋានុក្រមកម្ពុជាប្រជាធិបតេយ្យនៅកម្រិតណា ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះ?

៤៥. មេធាវីការពារក្តីមិនមានបំណងជំទាស់លោក ឆាំង យុ ឬក៏ជំទាស់ទៅនឹងតម្លៃកិច្ចការដែលបានបំពេញនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានតួនាទីសំខាន់ណាស់ក្នុងការតស៊ូមតិគាំទ្រជនរងគ្រោះ និងក្នុងដំណើរការផ្សះផ្សារជាតិទេ។ សំណួរនៅទីនេះគឺថា តើតួនាទីនោះស្របទៅនឹងតម្រូវការនៃការស៊ើបអង្កេតដោយយុត្តិធម៌ និងមិនលម្អៀងដែរ ឬយ៉ាងណា។ ចម្លើយគឺច្បាស់ជាមិនស្របទេ។ ក្នុងចំណោមបញ្ហាចម្រូងចម្រាស់ដទៃទៀតនៅ អវតក វាច្បាស់ណាស់ថា នៅមជ្ឈមណ្ឌលឯកសារកម្ពុជាសិទ្ធិក្នុងកាការពារក្តី គឺមិនសូវមានសារៈសំខាន់ចំពោះយុត្តិធម៌សម្រាប់ជនរងគ្រោះ ដែលគេគិតថា ជាអ្នកធានាឱ្យមានការដាក់ទណ្ឌកម្មចំពោះចុងចោទ ដែលកំពុងស្ថិតក្នុងការជំនុំជម្រះនាពេលបច្ចុប្បន្ននេះឡើយ។ ការទទួលយកកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយមជ្ឈមណ្ឌលនេះ ដោយគ្មានការពិនិត្យពីតុលាការ ឬការដេញដោលដោយផ្ទាល់មាត់ដោយនរណាម្នាក់ គឺរំលោភយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

ii. <u>កំណត់ហេតុច្បាប់ចម្លើយដទៃទៀត</u>

៤៦. កំណត់ហេតុស្តាប់ចម្លើយដទៃទៀតនៅក្នុងឧបសម្ព័ន្ធរបស់ កសព បានមកពីប្រភពជាច្រើន។ ក្រៅពីបណ្តឹងជនរងគ្រោះ និង កំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយ សចស និង កសព គ្មានកំណត់ហេតុស្តាប់ចម្លើយណាមួយបានមកពីការសម្ភាសន៍ដែលធ្វើឡើងដោយរដ្ឋឡើយ ដូច្នេះកំណត់ហេតុទាំងនោះមិនបានបំពេញលក្ខខណ្ឌតម្រូវនៃការទទួលយកតាមប្រព័ន្ធនៃវិធាន ៨២*ស្ទួន* ឡើយ។ ប្រសិនបើអង្គជំនុំជម្រះមិនដកចេញនូវកំណត់ហេតុទាំងនេះដើម្បីញែកឱ្យដាច់រវាងកំណត់ហេតុដែលអាចទទួល

[94] ឯកសារ **E-3/1648**, 'សម្លេងចេញពីមន្ទីរ ស-២១" ERN 00192667-00192932, p. 9 ។

ជាភស្តុតាង និងកំណត់ហេតុដែលមិនអាចទទួលជាភស្តុតាងបានទេ មេធាវីការពារក្តីនឹងរក្សាសិទ្ធិក្នុងការដាក់ការសន្និដ្ឋានបន្ថែមទៀតចំពោះភាពអាចយកជាការបាននៃកំណត់ហេតុទាំងនោះនិមួយៗ។

## ង. ដំណោះស្រាយ

៤៧. មេធាវីការពារក្តីសូម៖

ក. ស្នើដោយគោរពឲ្យស្វែងរកការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងបទដ្ឋានផ្នែកច្បាប់ដែលអាចយកមកអនុវត្តចំពោះការទទួលយជាភស្តុតាងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ដោយគ្មានវត្តមានសាក្សីនៅចំពោះមុខ អវតក ស្របតាមសេចក្តីសន្និដ្ឋានក្នុងចម្លើយតបបច្ចុប្បន្ន

ខ. ស្នើឲ្យពិចារណាថាប្រភេទនៃភស្តុតាងខាងក្រោមនេះ គឺមិនអាចទទួលយកបានដោយមិនមានការសួរដេញដោល។

i. កំណត់ហេតុផ្តល់សក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ រួមទាំងកំណត់ហេតុផ្តល់សក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់បុគ្គលដែលពាក់ព័ន្ធជាមួយជនជាប់ចោទ រួមមានគណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការយោធា។

ii. កំណត់ហេតុផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ឬរចនាសម្ព័ន្ធរដ្ឋបាលនៅស២១ ឬស២៤។

iii. កំណត់ហេតុផ្តល់សក្ខីកម្មពីរចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធទំនាក់ទំនងដែលសង្កត់ជាពិសេសទៅលើរចនាសម្ព័ន្ធក្នុងកម្រិតជាតិ និងភូមិភាគ។

iv. កំណត់ហេតុផ្តល់សក្ខីកម្មពីអំពើ និងការប្រព្រឹត្តរបស់បុគ្គលដែលជនជាប់ចោទត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយថាបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។

គ. កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា និងភ្នាក់ងារដទៃទៀតដែលមិនមែនជា អវតក ឬក៏រាជរដ្ឋាភិបាលកម្ពុជាគឺមិនអាចទទួលយកបានទេ។

ឃ. ស្នើដល់អង្គជំនុំជម្រះ ចាត់ទុក កំណត់ហេតុដែល ពិពណ៌នានៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា រាប់បញ្ចូលទាំងភស្តុតាងដែលខកខាននៅក្នុង កថាខណ្ឌ ខ (i) ឬ (ii) *ដូចខាងលើ* គឺមិន

អាចទទួលយកបានទាំងស្រុង, និង

ង. សូមរក្សាសិទ្ធិដើម្បី៖

i. បង្ហាញកំណត់ហេតុស្តាប់ចម្លើយបន្ថែមទៀត រួមទាំងភស្តុតាងដែលពិពណ៌នាក្នុងកថាខណ្ឌ (ខ) ខាងលើ។

ii. បង្ហាញកំណត់ហេតុស្តាប់ចម្លើយបន្ថែមទៀត ឬប្រភេទនៃកំណត់ហេតុស្តាប់ចម្លើយដែលមានសក្ខីកម្មបញ្ជាក់ពីឧក្រិដ្ឋកម្មនៅជិតនឹងជនជាប់ចោទបំផុត ឬបញ្ហាសំខាន់ក្នុងរឿងក្តី ប្រឆាំងនឹងជនជាប់ចោទ។ និង

ii. បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយដែលមិនអាចជឿជាក់បាន ឬប្រភេទនៃកំណត់ហេតុ ស្តាប់ចម្លើយដែលមិនអាចជឿជាក់បាន។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** | Michiel PESTMAN & Victor KOPPE